អ្នកស្រី ស៊ុយ ហៀង

# វាស្នានៃនាងណាត្រើ

អារម្ភកថា នុត ណារ៉ាង

LIBRARY



៣១៦.
១៥៧

មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
CEDORECK

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

# ទាស្លានៃនាងឈាក្រី

អក្សរសិល្ប៍ខ្មែរ
Littérature Khmère / *Khmer literatur*

**17**

Suy Hāṅ

# Vāsnā nai nāṅ Nāgri

អ្នកវាយអត្ថបទ : សួន ភិរុណ
អ្នកកែអត្ថបទ : ផ្លុង សោភា
ដឹកនាំការបោះពុម្ព : ឃឹម អ៊ុង

បោះពុម្ពឡើងវិញតាម "ខេមរៈបណ្ណាគារ"
Réimpression / *Reprint* : Khemarak Panakear, 1953
ព.ស. ២៤៩៦ គ.ស. ១៩៥៣

©, Cedoreck, Phnom Penh, 1999
**ISBN 2-86731-040-7**

៣១៦.១៥៧

អ្នកស្រី ស៊ុយ-ហៀង

# វាស្នានៃនាងណាត្រី

អារម្ភកថា
**នុត ណារ៉ាង**

LIBRARY
BUDDHIST INSTITUTE
៤៤៥១/៩៩

**មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ**
**CENTRE DE DOCUMENTATION ET DE RECHERCHE SUR LA CIVILISATION KHMÈRE**
***RESOURCE AND RESEARCH CENTRE ON KHMER CIVILIZATION***

**CEDORECK**

ព.ស. ២៥៤២ គ.ស. ១៩៩៩

# អារម្ភកថា -

កាលខ្ញុំមកដល់ទីក្រុងភ្នំពេញមុនដំបូងដើម្បីបន្តមធ្យមសិក្សា សៀវភៅប្រលោមលោកដែលខ្ញុំអានមុនគេពេលនោះ គឺ " **វាសនានៃនាងណាត្រី** " នេះឯង ។ តាំងពីតូចមកខ្ញុំតែងតែស្រឡាញ់ គោរពសៀវភៅណាស់ ហើយបណ្ណាគារខ្មែរសុទ្ធសាធនោះក៏មានតិចបំផុត ។ តាំងពីនៅកុមារម្ល៉េះ ខ្ញុំតែងចូលជារឿយៗ ក្នុងបណ្ណាគារទាំងឡាយ តាមដានមើលសៀវភៅថ្មី ៗ ហើយបពោសអង្អែលមិនអស់មិនហើយលើសៀវភៅណាដែលខ្ញុំចង់បាន ។ "ខេមរបណ្ណាគារ" នេះចាប់បើកដំបូងមានលក្ខណៈទំនើប រៀបចំល្អប្រណិត សៀវភៅគ្រប់រឿងសំរាប់សិក្សា ដូចជាវិជ្ជាទូទៅ ទាំងខ្មែរ ទាំងបារាំង ព្រមទាំងអ្នកបំរើជំនាញគួរសម សុទ្ធតែខ្មែរទាំងអស់ ។ ការដែលនាំឱ្យខ្ញុំកោតសរសើរ និងគោរពជាមនសិការថែមទៀតនោះ គឺបណ្ណាគារនេះដឹកនាំចាត់ចែងដោយស្រីខ្មែរម្នាក់ មានសម្ផស្ស និងកិរិយាជាអ្នកចេះដឹងខ្ពស់មួយ ប្រកបដោយឫកពាស្លូតបូត ចេះរាក់ទាក់រាប់រកសិស្សទាំងឡាយដូចខ្ញុំបាទពេលនោះ ។ រាល់ពេលសម្រាកខ្ញុំតែងតែ

ផ្ញៀតចូលបណ្ណាគារនេះ ស្ទើរខានមិនបាន ។ ថ្ងៃមួយស្រាប់តែឃើញសៀវភៅ " **វាសនានៃនាងណាត្រី** " នេះតាំងពេញទាំងទូ ខ្ញុំអត់ទ្រាំមិនបាន ក៏ដាច់ចិត្តទិញសៀវភៅនោះមួយ សុខចិត្តដកយកសោហ៊ុយសម្រាប់ទទួលទានបាយប្រចាំខែ នៅវត្តកោះនោះទៅចំណាយចុះ ។

ពេលនោះហើយដែលខ្ញុំបានដឹងថា អ្នកនិពន្ធគឺម្ចាស់ ខេមរៈបណ្ណាគារ ធ្វើឡើងនៅឆ្នាំ ១៩៥៣ នោះឯង ។ ខ្ញុំរិតតែស្ងើចថែមទៀត ។ តែមួយយប់នោះ ខ្ញុំក៏អានប្រលោមលោកនេះចប់ភ្លាម ។

ក្រោយមកជាយូរលង់ ផុតពីសម័យសម្លាប់ជាតិឯង នាឆ្នាំ ១៩៨០ ខ្ញុំក៏បានជួប លោកស្រី **ស៊ុយ ហៀង** ម្តងទៀត នៅ " *មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ* នាក្រុងប៉ារីស ធ្វើឱ្យខ្ញុំរំភើបក្រៃលែង ។ គាត់តែងមកជួយគាំទ្រដល់សមាគមយើងជាទៀងទាត់ ក្នុងការថែរក្សាវប្បធម៌ជាតិនៅបរទេសឱ្យបានគង់វង្ស ។ ខ្ញុំក៏បានសម្រេចថានឹងបោះពុម្ពសៀវភៅនេះជាថ្មីឡើងវិញ ហើយបំរុងនឹងជួបគាត់ដើម្បីសាកសួរ អំពីជីវប្រវត្តិអ្នកនិពន្ធស្រីខ្មែរដ៏ឆ្នើមម្នាក់ លើកតម្លៃឱ្យកូនខ្មែរក្រោយបានស្គាល់នូវស្នាដៃរឿងច្បងនេះ កុំឱ្យភ្លេចបាត់ពីស្មារតីវប្បធម៌ជាតិ ។ តែខ្ញុំចាំរហូតមកដល់ឆ្នាំ ១៩៨៩ ក៏រកគាត់លែងឃើញទៀត ឯសំបុត្រទាំងប៉ុន្មានដែលខ្ញុំធ្លាប់តែផ្ញើជូនគាត់ក៏ត្រឡប់មកវិញ បញ្ជាក់ថារកឈ្មោះមិនឃើញ ។ ខ្ញុំអស់សង្ឃឹម

ខាននបានចេញសៀវភៅនេះរហូតមកមិនដឹងជាគាត់នៅឯណា ? យ៉ាងដូចម្ដេចហើយ ?

ពេលនេះប្រជាជាតិយើងបានរួបរួមជួបគ្នា ប្រមែប្រមូលគ្រួសារមករស់នៅលើមាតុប្រទេសខ្មែរវិញ ទោះជាអ្នកខ្លះសម្រេចនៅក្រៅស្រុកកំណើតឯណាក៏ដោយ ក៏យើងបានសិទ្ធិជាខ្មែរវិញហើយ ។ ការកសាងស្ថាបនាជាតិ ក៏ក្លាយទៅជាកាតព្វកិច្ចរបស់ខ្មែរម្នាក់ ១ ដែលមានបន្ទុកបន្តជីវិតជាតិ ឱ្យមានសីលធម៌ស្វាហាប់ ចាប់កំណើតជាថ្មី រកសេចក្ដីសុខ សេចក្ដីចំរើនដល់សង្គមខ្មែរទាំងមូល ។

ដូច្នេះ វិស័យវប្បធម៌ក៏មានតួនាទីធំធេងណាស់ សម្រាប់ញ៉ាំងសតិអារម្មណ៍ខ្មែរ ឱ្យរក្សាបាននូវតម្លៃរបស់ខ្លួន ហើយធានាឱ្យការរីកចំរើនទាំងប៉ុន្មាន បានក្លាយទៅជាឈាមជ័ររបស់ខ្មែរពិត ១ ។ ការអនុវត្តន៍ណាមួយដែលមិនឈរលើតម្លៃសង្គម វប្បធម៌ទេនោះ គេប្រៀបបាននឹងដើមឈើគ្មានឫសដូច្នោះដែរ ។ ម្យ៉ាងវិញទៀត ការបណ្ដុះបណ្ដាលការអាន ជាមូលដ្ឋានគំនិតវិទ្យាសាស្ត្រ ធានានូវការរចនាស្នាដៃតាមការសរសេរជាអក្សរសាស្ត្រ វិទ្យាសាស្ត្រ ឬប្រវត្តិសាស្ត្រអ្វីៗ ទាំងអស់សម្រាប់បន្តពូជពង្សវង្សត្រកូល ឱ្យគេសន្សំពីជំនាន់មួយទៅជំនាន់មួយ ដែលបានស្រុតចុះស្ទើរបាត់បង់អស់រលីង។ ស្នាដៃអក្សរសិល្ប៍សព្វថ្ងៃរកគ្មានក្នុងបណ្ណាល័យ ឯក្នុងបណ្ណាគារក៏

គ្មានដែរ ។ ដូច្នេះកូនខ្មែរជំនាន់ក្រោយនេះលែងស្គាល់អ្វី ១ ពីរៀមច្បងមុន ១ ហើយ ។

ហេតុតនេះ " *មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ* " ដែលបានផ្ទេរពីប្រទេសបារាំងមកស្រុកកំណើតវិញ ក៏បានសម្រេចបន្តសកម្មភាពរបស់ខ្លួនតាមគោលជំហរពីដើមមក ដោយកែតម្រូវទៅតាមភាពជាក់ស្តែងរបស់ប្រទេសជាតិ ក្នុងស្ថានភាពថ្មី ។

ក្នុងចំណោមសកម្មភាពទាំងឡាយ អក្សរសិល្ប៍ជាចង្កោមបេតិកភ័ណ្ឌសរសេរមួយប្រភេទ ដែលមានតួនាទីទ្រទ្រង់នូវលំអភាសា ការតុបតែងពាក្យពេជ្រ ឃ្លាឃ្លោង ព្រមទាំងជួយជំរុញការតែងសេចក្តីឱ្យបានល្អ ដើម្បីជាសកម្មភាពសរសេរក្នុងវិស័យវិទ្យាសាស្ត្រ និងវប្បធម៌ទូទៅទាំងអស់ ។

ប្រលោមលោក " **វាសនានៃនាងណាត្រី** " បានចាប់បដិសន្ធិឡើងក្នុងបរិយាកាសសង្គ្រាមលោកលើកទី ២ ដែលប្រទេសខ្មែរយើងបានទទួលរងគ្រោះ ដោយគ្មានចេតនាអ្វីសោះ ។ ផលអាក្រក់នេះ បណ្តាលមកពីស្រុកត្រូវគេជិះជាន់ បាត់បង់នូវអធិបតេយ្យភាពរបស់ខ្លួន ។ ជម្លោះមហាអំណាចធំ ១ ជំនាន់នោះម្ខាងអាល្លឺម៉ង់ និងជប៉ុន លើជំហរហ្វាស៊ីស ជល់នឹងម្ខាងទៀតចងបក្សសម្ព័ន្ធ បារាំង អង់គ្លេស អាមេរិក លើជំហរមូលធននិយមសេរី ។ ឯទីលានក្តៅនៃ

ចម្បាំងគឺម្ខាងនៅអឺរ៉ុប ទ័ព Hitler និងទ័ពបារាំងរួមជាមួយទ័ពសម្ព័ន្ធមិត្ត មួយចំណែកទៀតនៅអាស៊ីប៉ាស៊ីហ្វិក រវាងទ័ពជប៉ុន អាមេរិក និងស្រុកនានា ដែលចំណុះអាណានិគមបារាំង និងអង់គ្លេស ។

លើដែនកម្ពុជា យើងក៏ត្រូវបានទទួលផលវិបាកដោយសារគេជិះជាន់យើងដែរ ។ អាណានិគមបានក្ដាប់ស្រុកខ្មែរតាំងពីចុងសតវត្សទី ១៩ មកម្ល៉េះ ។ មកដល់ចម្បាំងលោកលើកទី ២ (១៩៣៩-១៩៤៥) រដ្ឋាភិបាលបារាំង Petain ដែលជាបក្សពួកខាងអាល្លឺម៉ង់ (Hitler) - ជប៉ុន បានអនុញ្ញាត្តិឱ្យទ័ពជប៉ុនប្រើប្រាស់ទឹកដីខ្មែរធ្វើសង្គ្រាមតាមចិត្ត ។ ឥទ្ធិពលជប៉ុនក៏បានបំផុសចលនា*ឯករាជ្យ* ប្រឆាំងនិងពួកស្បែកស ពេលនោះហើយដែលខ្មែរចាប់មានការភ្ញាក់ស្មារតី អំពីឯករាជ្យភាពរបស់ប្រទេសនេះឯង ។ ( *សូមមើលសៀវភៅប្រវត្តិសាស្ត្រ* ) ការបណ្ដុះគំនិតថ្មី ៗ ដើម្បីជាអ្នកជានោះបានចាក់ឫសខ្ជាំងក្លា រីកដុះដាលតាំងពីនោះមក ។

ក្រោយមក អាល្លឺម៉ង់ និងជប៉ុនបានចុះចាញ់ទ័ពបក្សសម្ព័ន្ធ (Alliés) នៅខែ ៨/១៩៤៥ នៅអឺរ៉ុប។ តែនៅថ្ងៃទី ០៩ មិនា (9 Mars) ជប៉ុនបង្ខំឱ្យបារាំងប្រគល់សិទ្ធិអំណាចលើទឹកដីឥណ្ឌូចិនឱ្យជប៉ុនទាំងអស់ ដោយមានច្បាំងគ្នាខ្លះនៅលើប្រទេសខ្មែរដែរ ។ ដល់ ខែ តុលា ១៩៤៥ ទ័ពបារាំង-អង់គ្លេសមកយកឥណ្ឌូចិនវិញពីជប៉ុន ។ ពេលនោះ

ហើយដែលទ័ពបក្សសម្ព័ន្ធ Alliés (បារាំង-អង់គ្លេស) បានមកទម្លាក់គ្រាប់បែកជាលើកដំបូងលើរាជធានីខ្មែរ នៅចំផ្សារកណ្ដាលជ្រុងវត្តឧណ្ណាលោម ដែលបណ្ដាលឱ្យមានប្រលោមលោកនេះលើកជារឿង។

យើងខ្ញុំសូមបោះពុម្ពប្រលោមលោកនេះឡើងវិញ ដើម្បីគោរពស្នាដៃនិពន្ធអ្នកស្រី **ស៊ុយ ហៀង** លើកតំកើងពង្រីកចលនាអក្សរសិល្ប៍ ដែលកំពុងស្រុតស្ទើររលត់បាត់អស់ហើយ ឱ្យប្អូន ៗ កូនខ្មែរណែនាំគ្នាស្ដារ និងបណ្ដុះបំផុសព្រលឹងជាតិគ្រប់វិស័យឱ្យបានបាននូវអមតភាពរបស់ជាតិខ្មែរតទៅ ។

ភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៨

**នុត ណារ៉ាង**

# ជំពូកទី ១

*ក្រុងភ្នំពេញ កាលពីថ្ងៃ ១០ កើត ខែមាឃ ឆ្នាំរកា ពុទ្ធសករាជ ២៤៨៧*
*ត្រូវនឹងថ្ងៃទី ៧ តុលា ឆ្នាំ ១៩៤៥*

ពេលដែលព្រះអាទិត្យរះអណ្ដែតត្រសែតឡើង ជិតចំពាក់កណ្ដាលមេឃ កំដៅចោលកាន់តែខ្លាំងមកលើផែនដី នាឡិកាក៏វាយសូរឡើងឱ្យដឹងថាម៉ោង ១១ ហើយ ។

បណ្ដាជនទាំងឡាយ កំពុងតែខិតខំប្រឹងប្រែងប្រកបកិច្ចការងារសព្វសារពើ តាមធម្មតារៀងរាល់ប្រាណ ស្រាប់តែឮសូរស័ព្ទស៊ីរ៉ែនស្រែកឡើង"វ៉ី ៗ ខ្វី ញាប់ៗ" ។ បណ្ដាជនណាដែលនៅឆ្ងាយពីទីក្រុង ក៏បានទទួលសូរស័ព្ទសំឡេងជួងនឹងស្គរវាយឡើងលាន់ឮសូររំពង "ម៉ុងៗ តួងៗ" ខ្ទរចេញពីវត្តអារាមមក សូរសំឡេងនេះហើយគឺសញ្ញាប្រាប់ដំណឹងឱ្យបានដឹងថាមានសេចក្ដីវិនាសអន្តរាយមកដល់ហើយ ៗ ត្រូវប្រុងប្រយ័ត្នខ្លួន ។

ពេលនោះ ពួកក្រុមរដ្ឋបាល (អ្នកតម្រួតប្រទេស) ចេញដើរច្រវាត់ខ្វាត់ខ្វែង ប្រុងប្រយ័ត្នមើលការខុសត្រូវហាមរាស្ត្រមិនឱ្យដើរ

តាមផ្លូវ កាលណាបានឃើញស្រែកប្រាប់ទៅ ឱ្យរកលាក់ខ្លួនពួនក្នុងលេណដ្ឋាន (*ត្រង់សេ*) ។ រថយន្ត ទោចក្រយាន ត្រីចក្រយានផងទាំងឡាយ ដែលកំពុងតែបើកបរច្រវាត់ ប្រញាយពាសពេញផ្លូវ ត្រូវឈប់ ឬរត់រកគេហដ្ឋានរៀងៗ ខ្លួន ។

ចំណែកខាងផ្ទះចិន យួនធ្វើជំនួញនៅជិតផ្សារទាំងប៉ុន្មានបិទទ្វារស្រុសស្រាត្រីបៗ ឯអ្នកលក់ទំនិញក្នុងផ្សារតូច-ធំវិញ ក៏រៀបចំរបស់ភស្តុភារទុកដើម្បីនឹងភៀសខ្លួនរត់ចេញ អ្នកខ្លះឆោឡោស្រែកហៅប្ដីប្រពន្ធ ប្រមូលកូនប្រមូលចៅ រត់មីម្នាសំដៅរកលេណដ្ឋាន (*ត្រង់សេ*) ជ្រកសម្ងំលាក់បំពួនខ្លួន មិនយូរប៉ុន្មានព្រះរាជធានីដែលកំពុងតែអ៊ូអរក៏ទៅជាជាស្ងាត់ស្ងួនស្ងៀមឈឹង ។

លុះបានប្រហែលជា ២៥ នាទីក្រោយមក ស្រាប់តែឮស្នូរ "គ្ហឹលៗ គ្ហឹល" ញ័ររញ្ជួយរំជួល កក្រើកព្រះធរណី ផ្សែងខ្មៅក៏ផុសហុយទ្រលោមឡើងទៅលើអាកាស ឯមនុស្សផងទាំងឡាយរឹងរិតតែភិតភ័យ តក្កមាញ័ររន្ធត់លើសដើម ។

ចំណែកក្នុងលេណដ្ឋានរាជការ មានមនុស្សកាន់តែច្រើន រត់ចេញពីក្នុងផ្ទះប្រសាចមករកជ្រក អ្នកខ្លះមុខស្លក់ស្លាំងធ្វើឡិនឡង់ អ្នកខ្លះនឹកអំពាវនាវរកគុណបិតាមាតា គ្រូអាចារ្យ ខ្សឹប ៗ ជាប់នឹងមាត់ ។ ឯជាតិចិន យួន នឹកបន់ស្រន់រកអ្នកតា ក្នុងមាត់ខ្សឹប

រហ៊ឹមៗថា " អុងតាៗ " ។ អ្នកទាំងអស់គ្នាខំអំពាវនាវរាវរកគុណ សុំឱ្យជួយទ្រទ្រង់ជីវិតឱ្យបានឆ្លងផុតពីសេចក្ដីអន្តរាយ ក្នុងគ្រានេះ ។

សូរសំឡេង "គ្ហីលៗ" រំជួលរញ្ជួយកក្រើកព្រះធរណី នេះហើយ គឺជាសូរគ្រាប់បែក ដែលពួកសម្ព័ន្ធមិត្តហោះតាមអាកាសយានមក ទម្លាក់បម្រុងចង់បំផ្លាញទ័ពជប៉ុន ដែលជាបច្ចាមិត្តរបស់ខ្លួននៅក្នុង ប្រទេសយើង ។

# ជំពូកទី ២

## តា គឹមឡេង ដើររកកូន

លុះពេលដែលស្ងប់ស្ងាត់ចាត់ពីចលាចលនេះទៅ នៅវិថីហ្វីស៊ីញី[1] កន្លែងរងគ្រោះមួយ ជ្រុងខាងកើតជិតផ្សារកណ្ដាល មានតាម្នាក់គាត់មានវ័យចាស់អាយុប្រហែល ៦០ឆ្នាំ សក់ទើបតែនឹងដុះឡើងពីគោថ្មីៗ ស្គមសព្រោង មុខរាងវែង ស្បែកជ្រីវជ្រួញ ដំណើរកោងៗ តានោះឈ្មោះ"គឹម-ឡេង"ជាតិជាកូនកាត់ចិន ។ តា គឹមឡេងគាត់ឈរសំឡឹងមើលទៅផ្ទះគាត់ ដែលរលំចាក់បែកជាគំនររនោះនៅរង្វង់មុខមានទឹកភ្នែកហូររហាម ហើយយកដៃទាំងពីរគក់ឱរ៉ាទើបមានវាចាថា " អាវណ្ណី អាណាគ្រី ឱ ! កូនស្រីមាសឪពុកអើយទៅណាបាត់អស់ទៅ បានជាស្ងាត់សូន្យឈឹង ឪពុករកមិនឃើញទ្រូងអើយទ្រូងសែនស្ទើរប្រេះ កម្មអើយកម្មមកផ្ដល់ាំហើយណា " គាត់នៅឈរសញ្ជប់សញ្ជឹងសម្លឹងទៅរកកន្លែងដែលរងគ្រោះ ក្នុងចិត្តនឹកសង្វេគជាពន់ប្រមាណ ព្រោះធ្លាប់តែឃើញផ្ទះច្រូងច្រាង ដល់

---

១ - បច្ចុប្បន្នផ្លូវគេជោដំឱន (លេខ ១៥៤) ។

មកឥឡូវនេះ ផ្ទះអស់នោះស្រាប់តែរលំបាក់បែកខ្ទេចខ្ទី ទៅជាវាលដ៏ស្រឡះឃើញតែឥដ្ឋជាគំនរនៅពាសពេញ ហាក់ដូចជាមានខ្យល់កំបុតត្បូងដ៏មានកំលាំងធំអស្ចារ្យ មកបោកបក់កំទេចកំទី បំផ្លាញឱ្យរលំរលាយផ្ទះទាំងនោះ នឹងបំផ្លាញជីវិតមនុស្សទាំងឡាយជាអានេកកប្បការ ។

លុះមួយសន្ទុះក្រោយមក គាត់បានទទួលស្គាល់សំឡេងមនុស្សម្នាក់ដែលនៅជិតនិយាយមកថា "ចូរតាខំដើររកមើលកន្លែងឯទៀត ៗ ទៅ" ។ ពេលនោះគាត់នឹកកាត់ចិត្តដើរចេញពីកន្លែងនេះទៅ ខ្ទងកោងដំណើរមួយៗ ទប់ខ្លួននឹងដំបងឈើច្រត់ ចក្ខុរំពៃមើលនាយអាយ ក្នុងចិត្តព្រួយគ្មានរសាយ តាមគ្រប់ជំហានជើងនៃដំណើររបស់គាត់ លុះបានទៅដល់មុខវត្តឧណ្ណាលោម ចោលភ្នែកទៅស្រាប់តែឃើញចេតិយធំមួយ នៅជ្រុងខាងជើងព្រះវិហារបាក់រលំគ្របសង្កត់លើកុដិព្រះសង្ឃដែលឋិតនៅក្បែរទីនោះ ព្រះសង្ឃក៏មានសុគតខ្លះ រួចពីនេះទៅគាត់ក៏ដើរកាត់ថ្នល់តម្រង់ឆ្ពោះទៅមាត់ទន្លេ ប្រទះឃើញដីគ្រង់មាត់ច្រាំងផ្ទុះខ្ទង់ជ្រៅជំរៅប្រហែល ៥ម៉ែត្រ នៅជិតទីនោះ មានឃើញកូនទូកបាក់ជាកំណាត់ ៗ ប៉ើងខ្ចាយពីក្នុងទន្លេមកជាច្រើនឯក្នុងទន្លេមាន ទូកតូច-ធំ បាក់បែកខ្ទេចខ្ទីអណ្តែតព្រោងព្រាត ហាក់ដូចជាសំណាត់ មនុស្សក្នុងទូកទាំងប៉ុន្មានស្លាប់អស់គ្មានសល់ រួចពី

នោះមកគាត់ដើរតម្រង់សំដៅទៅរកមន្ទីរ ដែលគេយកមនុស្សរងគ្រោះទៅដាក់ ដល់ហើយចូលទៅរកពិនិត្យមើលមនុស្សរងគ្រោះថ្នាក់ទាំងអម្បាលម៉ាន ចាប់តាំងពីមនុស្សរបួសរហូតដល់មនុស្សអនិច្ចកម្ម ។ ក្នុងពេលដែលគាត់កំពុងតែពិនិត្យរកមើលកូន ស្រាប់តែឮសូរសំឡេងយ៉ាងក្រលួចស្រែកហៅមកគាត់ថា " លោកតា ៗ " តា គឺមឡេងភ្ញាក់ខ្លួនព្រើត រួចងាកមើលតាមខ្យល់នៃសំឡេងនោះទៅចំទិសខាងកើត ឃើញច្បាស់ជាក្មេងស្រីជំទង់ម្នាក់ ដែលវានៅបម្រើកូនគាត់ ។ កាលបើគាត់ក្រឡេកទៅឃើញក្មេងនោះ ក្នុងចិត្តនឹកអរព្រួចមានសេចក្ដីសង្ឃឹមឡើងថា " កូនរបស់អញ ច្បាស់ជារស់ជីវិតនៅក្នុងកន្លែងនេះ ម៉្លោះហើយសេចក្ដីទុក្ខព្រួយ សេចក្ដីអស់សង្ឃឹមទាំងប៉ុន្មានក៏រលាយសាបសូន្យពីក្នុងសន្ដានចិត្តគាត់ភ្លាម ហើយដើរឆ្ពោះទៅចំក្មេងនោះ រួចនិយាយថា " ភិរុណចុះអ្នកនាងឯង. . . នៅក្នុងកន្លែងនេះដែរឬ ? "

ភិរុណ - ចាំ ! នៅក្នុងទីនេះមិនឃើញទេ

គ គ ឡ - ឱ ! អម្បាញ់មិញនេះអញនឹកសង្ឃឹមក្នុងចិត្តថា ច្បាស់ជាអ្នកនាងឯងនៅក្នុងទីនេះជាមួយនឹងឯងដែរ ។

ភិរុណ- ចាំ ខ្ញុំចេះតែគន់មើលគាត់ដែរ ប៉ុន្តែមិនឃើញសោះ ទឹកភ្នែកហូរចេញមករហាម ទើបពោលតទៅទៀតថា " ឱលោក

អើយៗ ! អ្នកទៅឯណាបាត់ទៅ ប្រហែលជាចេញមិនផុតពីក្នុងផ្ទះនោះទេដឹង ?

ត គ ឡ. ចុះកាលនោះឯងនៅឯណា បានជាបែកគ្នាដូច្នេះ ?

ភិ រ. ចាំ កាលនោះ ខ្ញុំនៅក្នុងផ្ទះដែរ ប៉ុន្តែខ្ញុំនៅខាងមុខ ចំណែកអ្នកនៅខាងក្រោយជិតផ្ទះបាយ អ្នកមាលី យាយគ្រីម អ្នកតូច ប្អូនតូចនៅជុំគ្នាក្នុងផ្ទះបាយ កំពុងតែចំអិនម្ហូបអាហារ ដល់ឮសូរសន្ធឹកកញ្ចាល់ហោះៗមកធាបដំបូលផ្ទះ ៈ អ្នកស្រែកពីក្នុងមកថាឱ្យរត់ចេញៗ ខ្ញុំក៏ស្ទុះច្រានទ្វារខាងមុខចេញមក ។ ស្រាប់តែ . . . ស្រាប់តែខ្ញុំ . . . ខ្ញុំដួលសន្លប់ពុំដឹងខ្លួន លុះត្រាតែគេយកខ្ញុំមកដល់កន្លែងនេះ ទើបខ្ញុំបានដឹងខ្លួនឡើង "ភិរុណនាងក៏សើយសំពត់បង្ហាញជើងដែលត្រូវរបួសជាទម្ងន់ បង្ហាញខ្លួនប្រាណ រហូតដល់សំលៀកបំពាក់ឃើញប្រឡាក់សុទ្ធតែកំបោរសសំព្រុស ហើយធុំក្លិនដូចជាក្លិនរំសេវ ។

ត គ ឡ. ភិរុណ ឱចៅឯងនេះ ចំជាអាយុវែងមែន អើចុះពេលនោះ បើអ្នកឯងដឹងខ្លួនបានទាំងស្រែកដូច្នោះដែរ តើឯងបានឃើញនាំគ្នារត់ចេញមកដែរឬទេ ?

ភិ រ. ចាំ ខ្ញុំបានងាកមើលទៅមួយភ្លែត ឃើញគាត់រត់ចេញមកដែរ ប៉ុន្តែមិនដឹងជាផុតពីក្នុងផ្ទះឬទេ ។ ឯចំណែកខ្ញុំៗ ស្ទុះលឿនចេញ

មុនគាត់មក ដោយខ្ញុំនៅមុខស្រាប់ ។

តាផ្ទៀងត្រចៀកស្តាប់ពាក្យភិរុណសព្វគ្រប់ហើយ ទើបហូតយកកូនកន្សែងពីក្នុងហោប៉ៅមកជូតទឹកភ្នែក ដែលហូរធ្លាក់សស្រាក់ ហើយទាញយកកាបូបមកបើករាប់ប្រាក់ ឃើញមានចំនួនតែ ៥០រៀល គាត់ក៏ហូតយកក្រដាស ៥រៀល មួយសន្លឹកហុចទៅឱ្យភិរុណហើយនិយាយថា " តាគិតខំដើរទៅរកមើលអ្នកឯងទៀតហើយ ឯប្រាក់នេះឯងយកទៅទុកចាយចុះ "។ ភិរុណទទួលយកប្រាក់ ហើយយំខ្សឹកខ្សួលនៅទីនោះ តាដើរចេញទៅទាំងទឹកមុខក្រៀមក្រំ ភាន់ភាំងស្មារតីមិនដឹងជាគិតរិះរកទៅខាងណា ឈប់ឈរសញ្ជឹងគិតមួយសន្ទុះទើបនឹកភ្នកថា " គួរតែអញទៅត្រង់កន្លែងផ្ទះដែលបាក់វិញ មិនត្រូវលះបង់ចោលកន្លែងនោះឡើយ ។

# ជំពូកទី ៣

## តា គឹមឡេង ជួបនាងណាគ្រីលើគំនរផ្ទះ

លុះដល់ពេលសាយណ្ហសម័យ (ថ្ងៃរសៀល) តាបានដើរទៅដល់ជិតផ្ទះគាត់ដែលទទួលរងគ្រោះនោះ លុះចោលកន្ទុយភ្នែកពីចម្ងាយទៅ ស្រាប់តែឃើញនារីម្នាក់រាងខ្ពស់ស្រឡះ សក់រួញអង្កាញ់ទម្រង់មុខរាងសមរម្យ មិនវែងមិនខ្លីសម្បុរសជ្រះ អាយុប្រហែល ១៦ឆ្នាំ ដៃមួយកណ្ដៀតកាបូប ដៃមួយកាន់ដៃក្មេងស្រីតូចម្នាក់ ឈរបែរមុខទៅរកផ្ទះដែលបាក់នោះ គាត់នឹកអរព្រួចថា "ពិតជាណាគ្រី (កូនក្រមុំ) នឹងផេងរិន (ចៅ) របស់អញ" ។

ពេលនោះ តាគឹមឡេងរៀបហាមាត់ស្រែកហៅកូន ស្រាប់តែចិត្តមួយស្ទុះមកជែងទប់ភ្លាម មិនឱ្យហៅទៅវិញដោយគាត់នឹកគិតថាស្រមោលពុំពិតជារូបមនុស្សទេ ដោយសារតែអញនឹកពេកទៅៗ បានជាស្រម៉ៃឃើញដូច្នេះ ឬក៏ខ្មោចកូន នាងមកសំដែងរូបរាងឱ្យអញឃើញយ៉ាងនេះ ដោយកាលដែលនាងរៀបធ្វើមរណកាលទៅប្រហែលជាមានសេចក្ដីអាឡោះអាល័យចំពោះមករូបអញខ្លាំងពេក ។

កាលបើគាត់នឹកដូច្នោះហើយ គ្រាន់តែដើរសសៀរទៅឈរពីក្រោយខ្នងពុំមានបញ្ចេញសំឡេងហៅឡើយ ។

ចំណែកណាត្រី នាងកំពុងតែឈរជ្រប់កើតទុក្ខសម្រក់ទឹកភ្នែក និយាយលួងលោមប្រឡោមក្អួយកុំឱ្យវាស្រែកយំរកម្ដាយ ចក្ខុនាងខំសម្លឹងមើលទៅគំនរផេះនោះ ក្នុងទ្រូងសែនចម្លែងឥតឧបមា ប្រាថ្នាសូមឱ្យពួកទេវតាចុះមកជួយផ្ដុំបង្កើតគំនរផេះនោះឱ្យរបើកចេញក្នុងខណៈនេះ ដើម្បីឱ្យបានឃើញគ្រួសាររបស់នាងភ្លាមៗ កុំឱ្យនាងមានសេចក្ដីសង្ស័យក្នុងសន្ដានយូរអង្វែងទៅទៀត ។ មិនយូរប៉ុន្មាន ណាត្រីបង្វែរខ្លួនងាកមើលទៅក្រោយខ្នង ស្រាប់តែឃើញបិតានៅឈរជិតបង្កើយ ហើយម្ទីម្នាស្ទុះទៅស្រវាឱប . . . . . . . . ផេងវិនស្ទុះទៅចាប់ដៃជីតា . . . . . . . . ត្រកូលវេទនានេះ កាលបើបានជួបគ្នា ក៏នឹកអណោចអធម្មក្ដុកក្ដួលក្នុងចិត្តយ៉ាងខ្លាំង អត់ទ្រាំមិនបាននាំគ្នាទ្រហោយំបញ្ចេញសម្លេងយ៉ាងខ្លាំងៗ បង្ហៀរទឹកភ្នែកចេញមកសស្រាក់ ធ្លាក់ខ្វាយទៅលើព្រះធរណីអស់មួយសន្ទុះ ទើបនារីណាត្រីនាងសួរទៅឪពុកទាំងខ្សឹកខ្សួលថា :

ណាត្រី - កូនស្មានថា ផុតទីរំពឹងហើយមើលទៅចុះលោកតាទើបនឹងអញ្ជើញមកពីណា ? ហើយបងទៅឯណាទៅ ?

ត គ ឡ - កូនអើយ ពីព្រឹកមិញនេះ ឪពុកស្រាប់តែនឹកភ្នកចង់

ទៅវត្តព្រែកឫស្សី ដល់ម៉ោង៨ ឪពុកក៏ចេញដំណើរទៅរហូតដល់ម៉ោងមួយ បានឪពុកត្រឡប់មកវិញ ទើបតែមកដល់ត្រង់ស្ពានមុនីវង្ស ស្រាប់តែឃើញមនុស្សដើរឈូរឆ និយាយឡើងថា មានអាកាសយានមកទម្លាក់គ្រាប់បែកត្រូវជិតផ្សារកណ្ដាល ឪពុកគ្រាន់តែបានឮដំណឹងគេថាដូច្នោះ នឹកភ័យស្ទើរតែស្លុតស្មារតីប្រាសចេញពីក្នុងខ្លួន ហើយខំប្រឹងប្រវេប្រវាជ្រៀតជ្រែកគេឯងមក ស្រាប់តែ . . . . . ស្រាប់តែផ្ទះឃើញតែគំនរឥដ្ឋ ឪពុកក៏ខំដើររកគ្រប់ទីដំបន់រហូតដល់កន្លែងដែលគេយកមនុស្សរងគ្រោះទាំងប៉ុន្មានទៅដាក់ ឃើញតែភិរុណទេ វាប្រាប់ដំណឹងមកឪពុកថា កូនឯងនឹងផេងវិនពេលនោះនៅក្នុងផ្ទះដែរ ។ ឱកូនអើយ ! ឪពុកគ្មានសង្ឃឹមថាឯងនៅរស់ទេ អំណាចសេចក្ដីទុក្ខព្រួយគ្របសង្កត់ ឪពុកដើរស្ទើរតែនឹងរលំ ។ ចំណែកបងឯងវណ្ណី មាលី យាយក្រឹម ច្បាស់ជាកប់នៅក្នុងនេះហើយ ដោយគ្មានរត់ចេញមកមិនទាន់ ។

ណាត្រី - កាលនោះខ្ញុំនៅក្នុងសាលារៀនដល់ឮស្ករស៊ីរ៉ែន គ្រូឱ្យរត់ចូលក្នុងលេណដ្ឋាន លុះដល់ពេលស្ងប់ស្ងាត់វេលាណា ទើបគ្រូបើកឱ្យត្រឡប់មកផ្ទះវិញ ខ្ញុំក៏ទៅទទួលយកផេងវិនពីសាលារៀនរបស់វា ហើយដើរសំដៅមកករកផ្ទះ ស្រាប់តែចោលភ្នែកពីចម្ងាយទៅឃើញតែវាលស្រឡះ . . . . . មានប៉ូលិសយាមព័ទ្ធជុំវិញទីនេះ

ម្ល៉ោះហើយកូននៅឈរទទួលទុក្ខពីចម្ងាយ ។ ឱតា៎ៗ បានជ្រាបឬទេ? ខ្ញុំឮសូរគេនិយាយថា នៅក្នុងគំនរនេះមានឮសូរមនុស្សស្រែកថា : "លោកអើយជួយស្រង់ជីវិតខ្ញុំផង ខ្ញុំមិនទាន់ស្លាប់ទេ បើខ្ញុំបានរួចមក ខ្ញុំដឹងគុណលោកមិនខាន" ។

តាស្តាប់ណាត្រីនិយាយចប់អស់សេចក្តីហើយ គាត់ម្ទីម្ទាបបបួលកូនឡើងទៅលើគំនរឥដ្ឋនោះ មានកំពស់ប្រហែល ៣ម៉ែត្រ ហើយខំផ្ទៀងត្រចៀកស្តាប់ ប៉ុន្តែពុំបានឮសូរសំឡេងអ្វីឡើយ ដូច្នោះហើយក្នុងចិត្តគាត់ពុំមានគិតជឿស្មោះដល់ពាក្យគេនិយាយនោះប៉ុន្មានទេ រួចនាំកូនចុះមកវិញ ទើបតានិយាយទៅណាត្រីថា " ដល់ព្រឹកស្អែកឪពុកគិតនាំឯងនឹងផេងវិនយកទៅផ្ញើនឹងសំឡាញ់ឪពុកម្នាក់ ដែលនៅស្រុកចំការ (គៀនស្វាយ) ។

ណាត្រី - ទេតា៎ កូនមិនចង់ទៅទេ កូនសុំប្តូរនឹងបង នៅជួយកម្លាំងតា៎ហ្នឹងហើយ ។

ត គ ឡុ - ទេកូន ឯងអាសូរទ្រូងឪពុកទៅ ចូរនាងតាមគំនិតរបស់ឪពុកគិត ឯងកុំប្រកែកឡើយ នាំឱ្យឪពុកពិបាកចិត្ត ដ្បិតកូននៅក្មេងណាស់ ។ ចំណែកខ្លួនឪពុកៗ ចាស់ហើយ មិនសូវព្រួយបារម្ភចំពោះសេចក្តីស្លាប់ប៉ុន្មានទេ គាត់មានវាចាដូច្នោះហើយ ក៏ដកដង្ហើមធំៗ លើកដៃសំបូងសង្រួងបន្ទូលទៅលើ មានពាក្យខ្សឹបៗ

ក្នុងមាត់ថា " សូមឱ្យតេជះព្រះរតនត្រ័យនឹងពពួកទេពនិករទាំងមួយម៉ឺនលោកធាតុ សូមជួយថែរក្សាអាយុកូនខ្ញុំកុំឱ្យក្សិណក្ស័យ ទំរាំតែព្រឹកនឹងគិតរកគ្នាមករើគំនរនេះ បើឥឡូវនេះគំនរមានកំពស់ខ្ពស់ដល់ម្ល៉េះ ហើយសមពេលងងឹតជិតមកដល់ទៀតផង លុះស្រមោលងងឹតកាន់តែស្ទុះបមកចាំង ពន្លឺព្រះអាទិត្យបាត់សូន្យឈឹង នាំឱ្យមើលមុខគ្នាលែងច្បាស់ តាតឹមឡេង បបួលកូនចៅដើរចេញពីកន្លែងនេះដើម្បីទៅរកទីសំណាក់ក្នុងពេលរាត្រី គាត់ដើរចេញទៅក្នុងខណៈនោះ ឃើញមានទាហ៊ានជីពុន ២នាក់ មកឈរយាមត្រង់កន្លែងវង្គេ្រាះនោះ ។

# ជំពូកទី ៤

## យកណាគ្រីទៅឱ្យរស់នៅគៀនស្វាយ

លុះដល់ពេលហៀបទៀបជិតភ្លឺ ផ្កាយព្រឹកបញ្ចេញពន្លឺភ្លឺ ចិញ្ចែងឡើងលើមេឃា គន់មើលទៅព្រះចន្ទ្រាកាន់តែខ្សោយពន្លឺរស្មី ជិតអស្តង្គតណាស់ទៅហើយ នៅសល់តែពន្លឺស្រទន់ព្រាងៗ នឹងមាន ផ្កាយតូច_ធំរះអមជាបរិវារ មិនយូរប៉ុន្មានពពករសាត់ខ្មៅខ្វល់ផ្ដុំៗ គ្នាមកបាំងរស្មីព្រះចន្ទបាត់ៗ ឃើញមាន់ក៏រងាវ ឆ្លើយឆ្លងគ្នាគ្រប់ទិស ឱ្យដំណឹងដល់បណ្ដាជនឱ្យបានដឹងថា ជិតភ្លឺហើយ ។

ឯមនុស្សទាំងឡាយនាំគ្នាក្រោកចាកនិទ្រាគ្រប់កន្លែង ដើម្បី ប្រុងប្រៀបរៀបដំណើររត់ចាកចេញចោលទីលំនៅរៀងៗខ្លួន នៅ គ្រប់កន្លែងតាមផ្លូវ គេឃើញមានមនុស្សមីរដេរដាសដឹកជញ្ជូន ទ្រព្យសម្បត្តិ នាំកូនចៅធ្វើដំណើរទៅរកអាស្រ័យឯស្រុកស្រែចំការ ដោយអំណាចសេចក្ដីភ័យតក្កមា ក្រែងមានអន្តរាយមកបៀតបៀន ទៀត ម្ល៉ោះហើយទីក្រុងធ្លាប់តែអ៊ូអរ ពេលនោះក៏ទៅជាស្ងាត់ស្ងួន ជ្រៀប ឮសូរតែមាត់សត្វយំកញ្ជៀវខ្សៀវខ្វា ។

ចំណែកគ្រួសារតាតឹមឡេង ធ្វើដំណើរតាមរទេះគោរបស់បុរសម្នាក់ឈ្មោះចក់ ដែលគាត់ធ្លាប់ស្គាល់ ។ រទេះគោនោះ កាលបើចេញដំណើរទៅឮសូរង៉ឺតង៉ត១ រលាក់នឹងជង្ហុកគ្រលែងចុះគ្រលែងឡើង ឯអ្នកជិះរេខ្លួនតាមដែរ ។ ដំណើរក៏ជឿនលឿនជាលំដាប់ត១ មកពន្លឺកាន់តែភ្លឺច្រាលដេញឡើងបន្តិចម្តង១ ។

ណាគ្រីនាងបានគយគន់រំពៃគ្រប់តំបន់ហូរហែតាមផ្លូវ ឃើញមានពួកសត្វបក្សីបក្សាគៀងគូ ឈ្មោលញីលើចុងព្រឹក្សាត្រសងចុះឡើង១ ស្រែកយំទ្រហឹងអឺងកង ខ្លះហើរចាកទ្រនំទៅស្វែងរកចំណីអាហារទាំងហ្វូង១ ខ្លះពាំនាំយកមកឱ្យកូនដែលនៅចាំក្នុងសម្បុកទើបនាងងាក មើលទៅរុក្ខជាតិផងទាំងឡាយដែលនៅក្នុងស្រែចំការ ឃើញមានដុះតម្រៀបគ្នាជាជួរ១ពណ៌ខៀវស្រងាត់ ដើមខ្លះទៀតដុះប្រច្រៀតគ្នាដោយដុំ១ មានស្លឹកស្វិតស្រពោនធ្លាក់មែកធាងស្រយមទៅវិញទៅមករកគ្នា ហាក់ដូចជាមានសេចក្តីទុក្ខមកជិះជាន់ដូចជារូបនាងដែរ ហើយមើលទៅមនុស្សដែលកំពុងតែធ្វើការងារក្នុងស្រែចំការរបស់គេគ្រប់១ គ្នា ខ្លះបុក ដាំដក ខ្លះបេះផល្លាផលផ្សេង១ សប្បាយរីករាយនឹងគ្នាទៅវិញទៅមក នាងក៏នឹកឡើង ឱ្យអ្នកស្រុកអើយ អ្នកខំនាំគ្នាប្រកបកិច្ចការងាររបស់អ្នកដោយសុខក្សេមក្សាន្ត តាមធម្មតាឥតមានមោះមៃភិតភ័យអ្វីឡើយ ។

ចំណែកអ្នកនៅទីក្រុង គ្រានេះមានសេចក្តីកើតទុក្ខឥតឧបមា ពោះបង់ការងាររត់ចាកចេញចោលផ្ទះសម្បែង ដូចជារូបខ្ញុំនេះឯង ទទួលអកុសលផ្តល់ត្រូវបាក់បែកខ្ទេចខ្ទីផ្ទះសម្បែង វិនាសព្រាត់ប្រាស បងប្អូន និងទ្រព្យសម្បត្តិ ចាកចេញមកតែខ្លួនទទេ បិតាគិតយកទៅផ្ញើឱ្យនៅអាស្រ័យដោយសារនឹងគេ គួរឱ្យខ្ញុំអនិច្ចាប្រាណអ្វីម្ល៉េះ " ។ ណាត្រីកំពុងតែបញ្ជូនចិត្តស្លុងទៅកាន់អារម្មណ៍ផ្សេងៗ ដូច្នេះស្រាប់តែឮសូរសំលេងបិតានិយាយមកកាន់នាងថា " ណាត្រីៗ កូនដំណើរយើងកាន់តែជឿនចូលមកដល់ឃុំគគីរហើយ ត្រូវនៅតែមួយគីឡូម៉ែត្រទៀតទេ ដល់ផ្ទះនោះហើយ ចូរនាងប្រុងប្រៀបរៀបចំខ្លួនប្រាណឱ្យឆាប់ទៅកូន"។

លុះបន្តិចមក រទេះគោបានបរទៅដល់ទីនោះ គាត់ប្រាប់ទៅអាចក់អ្នកបររទេះឱ្យឈប់ ហើយហៅកូននឹងចៅចុះដើរសំដៅទៅតាមច្រកមួយខាងជើងថ្នល់ ។ នារីនាងដើរបណ្តើរសួរទៅឪពុកបណ្តើរថា ចាផ្ទះរបស់គេនោះសង់អំពីឈើឬ ?

ត គ ឡ - ទេកូន ផ្ទះនោះសង់អំពីឥដ្ឋប្រក់ក្បឿងមានរបៀបមិនខុសពីផ្ទះអ្នកក្រុងទេ សង់កំពស់ពីរជាន់មានទំហំទូលាយ ពីព្រោះគេជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភណាស់ដែរ នុ៎ះកូនបត់តាមផ្លូវកែងខាងមុខនេះទៅដល់ហើយ ។

ជូនជាពេលនោះ មានមនុស្សម្នាក់មាឌធំខ្ពស់ដំបងមាន ចំណាស់ប្រហែលអាយុ ៥០ឆ្នាំ មុខរាងវែងល្មម កាត់សក់ជ្រងខ្លីស្កូវ សមួយៗ នៅឈរចំពីមុខផ្ទះថ្មនោះ លុះគាត់ក្រឡេកឃើញតា គឹមឡេង ដែលត្រូវជាមិត្តយ៉ាងស្និទ្ធស្នាល ព្រមទាំងនារីនឹងក្មេង ស្រីតូចម្នាក់ដើរត្រសងពីចម្ងាយតម្រង់មកផ្ទះគាត់ៗ នឹកត្រេកអរ រីករាយមិនម្នាស្ទះចាប់ដៃទទួលរាក់ទាក់ ហៅចូលមកក្នុងផ្ទះរកទី កន្លែងដ៏សមគួរបបួលទៅអង្គុយ ទើបស្រែកហៅភរិយាឱ្យចេញមក ។ ឯតាគឹមឡេង បែរមុខនិយាយទៅនឹងកូនគាត់ថា : " ចូរកូនសំពះសួរ ទៅលោកអ៊ុំទាំងពីរ "ហើយបែរមកប្រាប់មិត្តវិញ នេះហើយជាកូន ស្រីពៅខ្ញុំឈ្មោះណាត្រី ឯនាងតូចនេះត្រូវជាចៅ ដែលម្ដាយរបស់វា ឈ្មោះនាងវណ្ណីមេម៉ាយ ។

តាប៉េង យាយស៊ឹម កាលបើបានឃើញនារីមានរូបឆោម លោមពណ៌ល្អស្រស់ប្រិមប្រិយដូច្នេះ គាត់ខំសំឡឹងមើលមិនដាក់ ភ្នែក ដោយនឹកពេញចិត្តជ្រិតខ្លួនឥតកូនស្រី ទើបរួសរាយនិយាយ ព្រមគ្នាឡើងថា យី ! ឯងខានឃើញវាតែប៉ុន្មានឆ្នាំសោះ ស្រាប់តែ ដល់មកឥឡូវនេះធំពេញរូបរាងម៉្លេះទៅហើយ លោកអើយកូនគេ នេះចំជាល្អឥតខ្ចោះ ។ នារីនាងនឹកអៀនឈ្លោក សំយុងស្រងូតមើល ចុះក្រោម ប៉ះភ្នែកទៅឃើញក្រឡាឥដ្ឋក្បឿរលោងព្រឹលចាំងស្រមោល

រូបផ្ញើក១ ដូចជាផ្ទុះកញ្ចក់ នាងនឹកក្តុកក្នុងចិត្តថា " ឱរូបអញអើយ មិនគួរកម្មអ្វីមកនាំឱ្យខ្ចាត់ភ្ជាតព្រាត់ប្រាសតែម្នាក់ឯង កណ្តែក កណ្តែងមកនៅដោយស្រុកគេយ៉ាងនេះ" ។

មួយសន្ទុះមក តាប៉េង យាយស៊ីម ដែលជាម្ចាស់ផ្ទះងាកមុខ ទៅរកមិត្តគាត់ ហើយនិយាយសំណេះសំណាលសាកសួរថា :

ត ប - ចុះបងម្តេចក៏បាត់មុខមាត់ប៉ុន្មានឆ្នាំមិនដែលឃើញមក លេងសោះ ? ចំណែកខ្ញុំចុះថាវរវល់ ខ្វល់នឹងថែរក្សាចំការច្បារដំណាំ ចុះបងនៅទីផ្សាររវល់អ្វីដែរ? ។ តាប៉េងនិយាយទាំងជក់បារីដែលមូរ នឹងស្លឹកសង្កែមានផ្សែងហុយទ្រលោម ។

ត គ ឡ - ឱប៉េងអើយ គ្នាមកនេះមកទាំងកើតទុក្ខធំគ្មានរបស់ អ្វីមកផ្ញើឯងទេ ថែមទាំងយកទុក្ខមកឱ្យអំពល់ដល់ឯងទៀតផង កាល ពីម្សិលមិញ ប៉េងឯងដឹងឬទេ ? ដែលកញ៉ាល់ហោះទៅទម្លាក់គ្រាប់ បែកនៅភ្នំពេញនោះ ?

ត ប - បាទ ខ្ញុំថ្វីក៏មិនដឹង ថែមទាំងឮសូររញ្ជួយខ្ទរមកដល់ នេះទៀតផង ចុះចំណែកបងស៊ូទ្រាំនៅដល់ណាទៀត ម្តេចមិននាំកូន ចៅដឹកជញ្ជូនទ្រព្យសម្បត្តិមកនៅឯនេះមក ខ្ញុំចេះតែខំទន្ទឹងមើល ផ្លូវតាំងពីព្រឹក ។

តាគឹមឡេង កាលបើបានឮសំដីមិត្តសួរមកចោះត្រូវចំទុក្ខខ្លួន

ដូច្នេះ ក៏នឹកក្ដួលអួលណែនដើមទ្រូង រកតែហាមាត់និយាយតបទៅមិត្តវិញមិនរួច ហើយធ្វើមុខស្រៀមអង្គុយនៅស្ងៀមឈឹង ។

ចំណែកតាប៉េង កាលបើបានឃើញអាការៈមិត្តដូច្នោះ គាត់បោះចោលកន្ទុយបារីចេញពីដៃភ្លាម ងយាយស៊ឹមអង្គុយផ្ទៀងកធ្វើមាត់ប្រហរ អ្នកទាំងពីរនាក់នឹកឆ្ងល់មិនដឹងជា តា គឹមឡេង មានហេតុដូចម្ដេច ? មួយសន្ទុះមកទើបតាគឹមឡេងហាមាត់និយាយទាំងរអាក់រអួលឡើងថា " ឱប្អូនអើយ កចាល់ហោះដែលហោះមកទម្លាក់គ្រាប់បែកពីម្សិលមិញនេះ" ត្រូវចំផ្ទះបង" ហើយគាត់និយាយរ៉ាយរាប់រឿងរ៉ាវសព្វគ្រប់ ឱ្យអ្នកទាំងពីរនាក់ស្ដាប់តទៅទៀត :

ទី ១. និយាយអំពីកូនក្មួយនិងមនុស្សម្នា ដែលនៅក្នុងផ្ទះទាំងប៉ុន្មាន បានទទួលរងគ្រោះថ្នាក់ដូច្នេះមកពីឮស្ករកញ្ជ្រៃ (ស៊ីរ៉ែន) ស្រែកញយៗ ពេកទៅ ស៊ាំត្រចៀកមិនដែលឃើញមានហុចឱ្យហេតុអ្វីសោះ។ មួយទៀតនៅក្នុងផ្ទះសុទ្ធតែស្រីៗ គំនិតខ្លីគិតតែប្រហែសធ្វេស ។

ទី ២. និយាយអំពីទ្រព្យសម្បត្តិទាំងប៉ុន្មានទុកក្នុងផ្ទះទាំងអស់ដល់ពេលទទួលគ្រោះថ្នាក់ដូច្នេះ ហើយគាត់ហួសចិត្តគិតមិនលេចទៅជាទ្រព្យមួយដែលឥតមានម្ចាស់ហួងហែងរក្សា ក្នុងចិត្តគាត់ប្រាថ្នាសូមតែទេវតាទុកអាយុឱ្យកូនរស់ចុះ ឯទ្រព្យធនស៊ឹមគិតតាមក្រោយ។

ទី ៣. និយាយអំពីនារីណាត្រី ។ចៅតូចនឹងខ្លួនគាត់បាន ចៀសផុតពីការអន្តរាយនេះ មកពីពេលនោះមិនបាននៅក្នុងផ្ទះ ។

ទី ៤. និយាយអំពីកន្លែងដែលបានទទួលរងគ្រោះទាំងអម្បាល ម៉ាន ចាប់តាំងពីទីជិតផ្សារកណ្តាលដែលជាកន្លែងផ្ទះគាត់ និង ចេតិយវត្តឧណ្ណាលោមរហូតដល់មាត់ទន្លេ ព្រមទាំងទីឯទៀត ៗ ដោយអន្លើៗ ដែលនាំបណ្តាលឱ្យសុគតព្រះសង្ឃ ស្លាប់បណ្តាជន គួរឱ្យនឹកសង្វេគតក់ស្លុតណាស់ ។ ឯទំពជប៉ុនគ្មានឃើញអន្តរាយអ្វី ឡើយ ។

ចំណែកខាងតាប៉េង យាយស៊ីម អង្គុយជ្រប់ចាំស្តាប់តា គីមឡេង និយាយសារស័ព្ទអំពីសេចក្តីវិនាសអន្តរាយយ៉ាងចំឡែក ដ៏ធំអស្ចារ្យ ដែលប្រទេសខ្មែរមិនដែលធ្លាប់ជួបប្រទះសោះ ។ លុះ តាគីមឡេង និយាយចប់សេចក្តីហើយ តាប៉េង យកដៃគក់ទ្រូងស្រែក ទ្រហោឡើងថា : " ឱ ! ពុទ្ធោអើយ ! មកត្រូវចេតិយវត្តឧណ្ណាលោម ផ្ទះសំបែងអ្នកធ្វើជំនួញ សុគតព្រះសង្ឃដែលលោកប្រព្រឹត្តតាមធម៌ វិន័យ ស្លាប់រាស្ត្រដែលជាអ្នកស្លូតត្រង់កាន់សុចរិតធម៌ទៅវិញ ។ ឯទំពជប៉ុនគ្មានឃើញអន្តរាយអ្វីសោះ "នេះហើយ" គេហៅថាចម្បាំង តែកើតចម្បាំងហើយរាស្ត្រតែងតែទទួលទុក្ខវេទនាដូច្នេះពុំខាន ។ គួរ ឱ្យនឹកសង្វេគដល់ទៅស្រុកគេដែលធំៗ មានកើតចម្បាំងរាំងជល់

យូៗ ឆ្នាំ សមរាស្ត្រទទួលរងទុក្ខវេទនាគ្រប់ចំពូកយ៉ាងណាទៅ ។

លុះតាប៉េងរៀបរាប់ចប់សេចក្ដីវេលាណា ទើបតាគឹមឡេង និយាយតឡើងថា :

ប្អូន ! បងមកឯងនេះ ប្រាថ្នារកសុំធ្វើកូនស្រីនឹងចៅនេះផង តាមតែឯងអាណិតមេត្តាស្ដីប្រដៅប្រដៅដូចកូនដូចចៅផងចុះ ទំរាំតែរួចទុក្ខបងមកយកទៅវិញ ។

ត ប - ចុះមានការខុសត្រូវអ្វីបង ចំណែកចិត្តខ្ញុំសព្វថ្ងៃរាប់អានស្រឡាញ់បងទុកដូចជាបងបង្កើតរបស់ខ្ញុំ អើចុះបងមានប្រាក់ទុកធ្វើសោហ៊ុយខ្លះដែរឬទេ ?

ត គ ឡ - ឱលាក់ចាំងអ្វីប្អូនអើយ ក្នុងខ្លួនបងជាប់បានប្រាក់តែ ៥០រៀល ហើយនឹងខ្សែមាសមួយខ្សែ ទម្ងន់ប្រហែលជាមួយដម្លឹង ដែលប្រគោងជាប់នឹងនាឡិការដក់នេះ " ថាហើយគាត់ទាញមកបង្ហាញ រួចនិយាយតទៅទៀតថា " កាលណាត្រឡប់ទៅវិញគិតយករបស់នេះទៅលក់ ដើម្បីយកប្រាក់ទៅធ្វើជាសោហ៊ុយ រកជួលមនុស្សរើគំនរនោះ ។

ត ប - យី ! បើដូច្នោះ បងយកប្រាក់ពីខ្ញុំ ៥០០រៀល ទៅទុកទប់សោហ៊ុយចុះ បើកាលណាខ្វះខាតម្ដេចម្ដា ឬក៏បងនៀយកម្លាំងពេកសូមឱ្យឆាប់ៗ ប្រាប់ដំណឹងមកខ្ញុំណា ខ្ញុំនឹងឱ្យស៊ីណាតវាទៅ

ជួយ ឥឡូវវាចេញទៅឯណាបាត់តាំងពីព្រឹល១ៗ ម៉េះ និយាយដូច្នេះ ហើយដើរសំដៅទៅទូរចាក់សោរយកប្រាក់ ៥០០រៀល មកហុចឱ្យមិត្ត ។

តគឡ - ប្អូន បងអរគុណឯងណាស់ ចុះចំណែកស៊ីណាតឥឡូវនេះ តើធំប៉ុនណាហើយ ? ឯងសព្វថ្ងៃមានកូនប្រុសតែមួយហ្នឹងឬ ? "។ តាគឹមឡេងទទួលយកប្រាក់ពីដៃតាប៉េងហើយ ស្រដីសួរក្នុងចិត្តនឹកអរជាពន្ទឹក ដោយហេតុតែខ្លួនទាល់គំនិតនឹកខ្វល់ទ្រូងសែនចង្អៀត ដល់ឃើញមិត្តហុចប្រាក់រយឱ្យមកក្នុងចិត្តនឹកអរឥតឧបម៉ា ។

ឱ ! គួរឱ្យអាសូរដល់តាគឹមឡេងណាស់ ធ្លាប់ជាអ្នកមានធនធានរាប់សែន ឥឡូវនេះចុះថ្នាក់ ធ្លាក់ទល់ដល់ម៉េះ ។

តប -បាទបង កូនខ្ញុំមានតែមួយហ្នឹង ចូលមកក្នុងឆ្នាំហ្នឹងទៀតអាយុបាន ២៣ឆ្នាំហើយ ប៉ុន្តែខ្ញុំមិនទាន់គិតគូរកប្រពន្ធកូនឱ្យទេព្រោះគំនិតវានៅខ្ចីពេក បង្អង់ចាំដល់ទៅឆ្នាំក្រោយៗ បានគិតគូរកឱ្យ ។

ពេលនោះ ព្រះសុរិយារះកាន់តែរុងរឿង ចោលពន្លឺរស្មីភ្លឺព្រោងព្រាតមកលើពសុធា តា គឹមឡេង ប្រញាប់ប្រញាល់លាមិត្តហើយហៅកូនចេញមកក្រៅទើបផ្តាំថា :

ឱណាត្រី ប៉ាលាកូនត្រឡប់ទៅភ្នំពេញវិញហើយ នាងនៅទីនេះ

ចុះកូន ចូរថ្លៃខំយកចិត្តទុកដាក់បម្រើ ប្រើប្រាស់គេកុំធ្វេសប្រហែស ព្រោះយើងមកនៅអាស្រ័យដោយសារគេ កុំឱ្យគេថ្កោលគំនិតខ្លួនបាន ម្យ៉ាងទៀតឪពុកសូមផ្តាំ ចូរកូននាងចាំរៀបឯងជាស្រី កុំដើរទៅលេងដោយផ្ទះគេ ជាការមិនគប្បី ឬស្រដី អ្វីៗ នាងតោងគិត កុំបណ្តែតបណ្តោយឱ្យធ្លោយគំនិតនាំឱ្យសត្រូវនៅជិត ៗ ស្តាប់បានមើលងាយដល់ប្រាណ ចំណែកផេងរិនជាក្មួយនៅក្មេងតូចណាស់ កូនតោងគិតកុំឱ្យវាដើរទៅលេងជិតទន្លេ ឬបឹងបួរ នឹងអស់ទាំងសត្វពាហនៈ ក្រែងជួនមានគ្រោះថ្នាក់ប៉ះពាល់ដល់ខ្លួនវា" ឪពុកទៅមិននៅយូរទេ គង់តែវិះរេ ឆាប់មកប្រាប់កូនឱ្យបានដឹងកិច្ចការ ចូរនាងកុំព្រួយបារម្ភគិតទៅឪពុកណា ក្រែងលោបណ្តាលទៅជាកើតជម្ងឺដម្កាត់ចាប់ក្នុងខ្លួនថ្លៃ ។ គាត់ផ្តាំកូនដូច្នោះហើយ ទើបហៅផេងរិនមកជិតប្រាប់ថា " ផេងរិនចូរចៅនៅនឹងម៉ាក់មីងឯហ្នឹងហើយ តាត្រឡប់ទៅភ្នំពេញវិញរកមើលម្តាយនាង ។

តាគីមឡេងនិយាយផ្តែផ្តាំកូន និងចៅ សព្វគ្រប់អស់សេចក្តីហើយៗ ដើរចេញទៅៗ ទាំងទុក្ខទឹកភ្នែកហូរចេញរហាមតាមផ្លូវ ។ ចំណែកនារី នាងឈរសំឡឹងមើលតាមក្រោយខ្នងឪពុកត្រាតែផុតកន្ទុយភ្នែក ទើបងាកបែរពួនឃុំក្បឹកក្បួល មិនយូរប៉ុន្មានឮមាត់យាយស៊ីមប្រកួកហៅឱ្យចូលទៅក្នុងផ្ទះ ។

# ជំពូកទី ៥

## ណារត្រីនៅផ្ទះគេមានកម្លោះមិនល្អ

ចាប់តាំងពីថ្ងៃនោះមក នាងខំយកចិត្តទុកដាក់ចំពោះកិច្ចការសព្វសារពើរបស់តាយាយ ពុំហ៊ានធ្វេសប្រហែសឡើយ នាងគ្មានគិតនឿយហត់ ទោះបីយប់ថ្ងៃឱ្យតែមានកិច្ចការមកដល់ ពេលថ្មើរម៉ោងនាងស្ទុះទៅប្រញាប់ប្រញាល់ទទួលធានារ៉ាប់រងលើខ្លួន ចាប់តាំងពីធ្វើបាយទឹកម្ហូបអាហារសព្វកិច្ចការនៅក្នុងផ្ទះ រហូតដល់កិនស្រូវបុកអង្ករ នាងចេះតែខំប្រឹងត្រដេវត្រដរធ្វើកើតទាំងអស់ គួរឱ្យអាសូរណាត្រីណាស់ នាងខំធ្វើការឱ្យគេគ្មានរហែ ។

ឯតា-យាយ តាំងពីបានណាត្រីចូលមកនៅអាស្រ័យជាមួយវេលាណា គាត់បានធូរកំលាំងជាច្រើន ដោយសារស្នាដៃនាងទទួលរ៉ាប់រងធ្វើជំនួសសឹងតែគ្រប់ចំពូកទាំងអស់ ម្ល៉ោះហើយគាត់មានសេចក្តីរីករាយសប្បាយរាល់ពេលវេលា ហើយតែងតែចំណាយប្រាក់កាស ផ្តល់ឱ្យនាងទុកចាយវាយជារឿយៗ ។

ចំណែកអ្នកនៅជិតខាង គេតែងតែលបនិយាយសរសើរប្រាប់

គ្នាថា " ណាត្រីជានារីមួយគួរឱ្យពេញចិត្តណាស់ នាងមានកិរិយាមារយាទសុភាពរាបសារ ឫកពារនឹងនួនមើលទៅសមជាកូនគេមានពូជមែន ប៉ុន្តែមកនឹកអាណិតជ្បិតនាងមកជ្រកនៅក្នុងផ្ទះនេះ មានមនុស្សម្នាក់ដែលធ្លាប់កាន់កិរិយាមារយាទខិលខូច គេឯងដឹងឮពេញទាំងក្នុងស្រុក (គឺរូបស៊ីណាត) កូនប្រុស តាប៉េង យាយស៊ីម ដែលជាម្ចាស់ផ្ទះនោះ ។

ស៊ីណាតរាងទាបមាឌធំក្រអាញ សក់កាត់ឡុងសុងរួញអង្កាញ់ផ្ទត់ៗ មុខមូលសាច់សស្អាត ឥឡូវនេះសមមួយថ្ងៃៗ គ្មានធ្វើការអ្វីបន្តិចបន្តួចសោះ គិតតែតែងខ្លួនស្លៀកពាក់ហ៊ីហាឥតលោះមួយវេលាណាទេ ។

* * *

ស៊ីណាត កាលបើឃើញរូបឆោមលោមពណ៌នារីល្អ ហាក់ដូចជាស្រីទេពកញ្ញាធ្លាក់ចុះពីស្ថានសួគ៌ា មកឋិតនៅជិតក្បែរខ្លួនវេលាណា យុវជននេះតែងតែមានចិត្តសោមនស្សសប្បាយរីករាយពន់ប្រមាណ មួយថ្ងៃៗ គិតលៃរំពៃឱ្យតែមានពេលវេលាណាស្ទាត់ល្មមនិយាយកិច្ចការលួងលោមឱ្យនារីស្រឡាញ់ខ្លួន ។

ចំណែកខាងនារី កាលបើដឹងខ្លួន ដោយឃើញកិរិយាស៊ីណាត

ប្លែកខុសពីគេដូច្នោះហើយ នាងចេះតែនឹកគិតបារម្ភភ័យខ្លួន មុខ ពុំរីក ណាមួយចិត្តគិតទៅបិតា ណាមួយព្រួយបារម្ភខ្លាចថ្លោះការ ដោយសេចក្ដីព្រហើនរបស់ស៊ីណាត ។ ពេលយប់ៗ គ្រប់រាត្រី នាង តែងតែអុជធូបទៀនបន់ព្រះ សំពះទេវតា សុំឱ្យបិតានាងរួចពីទុក្ខសុំ ឱ្យស្រុកឈប់ច្បាំង ហើយនឹងសូមឱ្យនាងគេចផុតពីស្នាដៃស៊ីណាត ដែលជាមនុស្សនាងពុំគាប់ចិត្ត ។

# ជំពូកទី ៦

## ការជួបជាមួយទវ៉ា នាំសំបុត្រឪពុកណាត្រីមក

មានថ្ងៃមួយព្រះសូរិយាជ្រេទេទោទន់ណាស់ទៅហើយ លិចប្រផិតចុងព្រឹក្សា ហើយចោលពន្លឺរស្មីពណ៌ក្រហមច្រាលផ្ទិនផ្ទៅមួយចំហៀងមេឃពីទិសខាងលិចមក ។

ណាត្រីនាងព្រួយចិត្តគិតមិនលេច ទើបនឹកភ្ញកដើរទៅរកទីវាលមួយ វាលនោះមានស្មៅលូតលាស់ឡើងខៀវស្រងាត់ ដែលជាកន្លែងនៃអ្នកគង្វាលគោក្របី ដើម្បីចង់លំហែចិត្តឱ្យរសាយអំពីសេចក្តីទុក្ខ មិនយូរប៉ុន្មាននាងក៏បានទៅដល់ ក្រឡេកទៅយល់ដើមរំដួលមួយដើមដុះក្បែរទីនោះ មានបែកមែកសាខាថែមទាំងរីកផ្កាសំពោងព្រោងព្រាតពណ៌លឿងព្រឿងៗ ពាសពេញលើដើម ឯវាយោផាត់ផាយបក់ក្លិនបុប្ផសាយភាយៗ ក្រអូបឈ្ងុយឈ្ងុបមកគួរឱ្យជាទីមនោរម្យដល់ទឹកចិត្តពន់ប្រមាន ណាត្រីចូលទៅអង្គុយទម្រេតខ្លួនក្រោមដើមនោះ ចក្ខុនាងរំពៃមើលទៅពួកអ្នកគង្វាលគោក្របី ឃើញពួកក្មេងៗ នាំគ្នារត់លេងស្រែកហ៊ោកព្រៀវទ្រហឹង

អឹងកង ខ្លះលេងល្បែងស៊ីសងមានហើប នឹងកូនចាប៊ីកជាដើម ។ ពេលនោះមានក្មេងប្រុសជំទង់ម្នាក់ស្រែកច្រៀង សំឡេងយ៉ាងអន្ទង់អន្ទោចឡើងថា :

" ឱព្រះសូរិយាជ្រេទេទាបទៅ   រស្មីគងនៅលើខ្នងភ្នំ
ពពករសាត់ផាត់ជុំៗ   ខ្លួនខ្ញុំកើតទុក្ខពន់ប្រមាណ ។
ស្រណោះស្រុកខ្មែរធ្លាប់បានសុខ   ឥឡូវកើតទុក្ខឥតស្រាកស្រាន្ត
អ្នកនៅទីក្រុងទាំងប៉ុន្មាន   ដកប្រាណរត់ទៅស្រែចំការ ។
មិនបានទ្រាំនៅក្នុងទីក្រុង   ក្រែងផងអន្តរាយគ្មានខ្លឹមសារ
វិនាសបង់ខាតខូចអាសារ   ដល់ក្រុមគ្រួសារទ្រព្យសម្បត្តិ ។
អនិច្ចាទឹកឡើងសែនកំសត់   មិនគួរប្រាសព្រាត់អ្នកខ្វាយខ្វាត់
មានគុណធ្ងន់ក្រៃតាមពាក្យសត្យ   មកនៅណែបចាត់នឹងផ្ទះគេ ។
ក្បាលមួយម្នាក់ឯងចម្បែងក្រៃ   កើតទុក្ខរាល់ថ្ងៃឥតទំនេរ
ទុក្ខអើយកម្មខ្ញុំធ្ងន់ម្ល៉េះទេ   ទុក្ខទ្វេរត្រួតថែមជាច្រើនគ្រា ។
ពេលយប់ប្រាសគេងៗ ទាំងទុក្ខ   ពេលភ្ញាក់ៗ មុខទាំងវេទនា
ទឹកលោកមានគុណរាល់វេលា   និកម្មវេរាឥតប្រណី ។
ស្រណោះទីវាលធំល្វឹងល្វើយ   វាលអើយមានស្មៅដុះខៀវខ្ចី
ក្លិនផ្ការំដួលរីកថ្មីៗ   គួរឱ្យបេក្ខិពន់ប្រមាណ៍ ។

ពេលដែលក្មេងនោះ វាកំពុងតែស្រែកច្រៀងឡើង នាងង៉ើយ

មុខមើលឆ្ពោះទៅ ស្គាល់ច្បាស់ជាអាកេងផ្ទះរបស់វានៅភ្នំពេញជិតផ្ទះនាង ។ ផ្ទះអាកេងបានទទួលគ្រោះថ្នាក់បាក់បែកអស់ដែរ ឪពុកម្ដាយ បងប្អូនវាទទួលអនិច្ចកម្មទាំងអស់គ្នា រស់នៅតែរូបវាម្នាក់ឯង ដោយពេលនោះវាពុំបាននៅក្នុងផ្ទះ លុះវាច្រៀងចប់ហើយ នាងស្រែកហៅឱ្យមកជិត ហើយហុចក្រដាសប្រាក់មួយរៀលទៅឱ្យអាកេងទទួលប្រាក់ធ្វើមុខយ៉ាងស្រងូត សំពះអរគុណមករកនាងវិញ ទឹកភ្នែកវាក៏ហៀរហូរមក ។ ចំណែកនាងធ្វើមុខស្រពោន ហើយចេញទឹកភ្នែកព្រិចៗ មកតាមវាដែរ បន្តិចមកមិត្តរបស់អាកេងស្រែកហៅឱ្យចាប់គោត្រឡប់ទៅទីលំនៅវិញ ពេលនោះអាកេង ក៏បែកចេញពីនាងទៅ ។

គាប់ជួនក្នុងវេលាហ្នឹង មានយុវជនម្នាក់អាយុប្រហែល ២០ឆ្នាំ រាងខ្ពស់ល្មម មាឌតូចស្តើង សម្បុរសណ្តែកបាយ មុខរាងវែង ថ្ពាសរាងខ្ពស់ធំទូលាយសក់កាត់ឡុងសុង ភ្នែកតូច ច្រមុះរាងកោង (ឈ្មោះវ៉ា) វ៉ាបានសិក្សាវិជ្ជាជាប់សញ្ញាប័ត្រឧត្តមវិជ្ជា (ឌីប្លូម) ទើបតែឈប់លាចេញពីសាលាវិទ្យាល័យ ស៊ីសុវត្ថិមក អ្នកជាកូនកំព្រាឥតមាតាបិតាឡើយ ហើយជាអ្នកខ្សត់ទ្រព្យសម្បត្តិផង សព្វថ្ងៃនៅពឹងពាក់អាស្រ័យជាមួយនឹងបងស្រី ដែលជាអ្នកទីទាល់ក្រដែរ ។

យុវជននេះដើរពីនាយ សំដៅចំមករកនាងធ្វើដំណើរយ៉ាង

វិនាសបង់ខាតខូចអាសារ ដល់ក្រុមគ្រួសារទ្រព្យសម្បត្តិ ។
អនិច្ចាទឹកឡើងសែនកំសត់ មិនគួរប្រាសព្រាត់អ្នកខ្វាយខ្វាត់
មានគុណធ្ងន់ក្រៃតាមពាក្យសត្យ មកនៅណែបចាត់ទឹងផ្ទះគេ ។



ក្នុងភូមិជិតជាមួយផ្ទះដែលអញមកជ្រកនោះដែរ ចុះគេដើរតម្រង់មករកអញមានការណ៍អ្វីអេះ "នាងនឹកដូច្នេះហើយ ក៏ឱនមុខជ្រប់ឈ្ងោកមើលទៅដី ក្នុងចិត្តនឹកភ័យដោយខ្លួនជាស្រី ពុំដែលធ្លាប់ជួបប្រទះជាមួយនឹងបុរសក្នុងទីស្ងាត់ដូច្នេះសោះ ម៉្លោះហើយសេចក្ដីភ័យបារម្ភនឹងការអៀនខ្មាស់ ច្រាលច្របល់ឡើងក្នុងទ្រូងនាងមួយរំពេច បេះដូងដាលញ័រចំប្រប មុខឡើងឈាមក្រហមច្រាលមកភ្លាម ហើយពុំហានក្រឡេកមើលទៅបុរសទៀត ទើបក្រោកឡើងបម្រុងដើរគេចចេញឱ្យផុត ទើបតែនឹងឈានជើងដើរបាន ២-៣ ជំហានប៉ុណ្ណោះ ស្រាប់តែឮសូរសំឡេងបុរសស្រែកហៅមកថា " ខ្ញុំមានដំណឹងមួយនាំមកជូននាង សូមនាងកុំអាលអញ្ជើញទៅ "។ ណាត្រីកាលបើបានឮសូរពាក្យវ៉ា ដូច្នោះ នាងនឹកឆ្ងល់ ទើបឈប់បង្វែរខ្លួនមើលមកវ៉ាវិញ ។

វ៉ា - ខ្ញុំខំដើររកនាងនាំសំបុត្រមួយច្បាប់ពីលោកឪពុកនាងមកជូន ។

ថាហើយវ៉ាហូតសំបុត្រពីហោប៉ៅហុចទៅឱ្យនាង ។

ណាត្រី - ខ្ញុំសូមអរគុណបង "នាងលូកដៃទៅទទួលសំបុត្រយ៉ាងរហ័ស ហើយធ្វើបដិសណ្ឋារៈ ដោយការគួសមទៅរកបុរសដែលបាននាំដំណឹងដែលនាងទន្ទឹងមកប្រាប់នាង តែនៅក្នុងចិត្តនាង

នឹកថប់ឥតស្បើយ គិតចួល់ម្តេចឡើយបិតាមិនឃើញមក នឹកភ័យផង អរផង ទើបហែកសំបុត្រយកសេចក្តីមកអានឃើញថា :

*ភ្នំពេញនៅថ្ងៃ ២៣ ខែ តុលា ឆ្នាំ១៩៤៥*

*ដំណឹងរបស់ឪពុក ប្រាប់មកកូនឱ្យបានដឹង កូនអើយ ! ឪពុកបានត្រឡប់ពីទីនេះទៅវិញ ខំព្យាយាមរើគំនរឥដ្ឋនោះអស់វារៈ ៧ថ្ងៃ ទើបបានឃើញខ្មោចវណ្ណី បងឯងនឹងនាងម៉ាលី ។ ខ្មោចអ្នកទាំងពីរនេះស្លាប់ជិតទន្ទឹមគ្នា មានផ្ទាំងបេតុងអាមេដុំធំៗ មកគ្របសង្កត់លើមានឃើញរបួសជាដំណាំសមជាស្លាប់ភ្លាមៗ មិនមែនស្រែកហៅឱ្យគេជួយនោះទេ ។*

*ឯយាយក្រឹម ប្រហែលជាស្លាប់នៅក្នុងផ្ទះបាយខាងក្រោយនោះហើយ បានជារកខ្មោចពុំឃើញសោះ ព្រោះនៅខាងក្រោយនោះ មានគ្រាប់បែកធ្លាក់មកចំត្រូវខ្ទេចដី មានជំរៅប្រហែលជា ៥ម៉ែត្រ ឃើញមានទឹកចេញមករាងក្រហមហាក់ដូចជាឈាម ឥឡូវនេះឪពុកបានទិញក្តារម្ស្លសមកដាក់ខ្មោចទាំងពីរនាក់ ដង្ហែនាំយកទៅបូជានៅវត្តស្វាយពពែរួចហើយ ។ ឯចំណែកទ្រព្យសម្បត្តិរបស់យើងទាំងប៉ុន្មានពួកអ្នករើកកាយគំនរទាំងនោះ លួចយកបាត់បង់អស់គ្មានសល់ សូម្បីតែមាសពេជ្របន្តិចបន្តួចដែលខ្មោចនោះ*

*ពាក់ជាប់នឹងខ្លួន ក៏វានាំគ្នាលួចប្រទាញផ្ដាច់យកទៅអស់ដែរ ដោយហេតុតែឪពុកម្នាក់ឯង ចេះតែវង្វេងស្មារតីមើលប្រយ័ត្នពុំឈ្នះ ឥឡូវនេះឪពុកបានទៅនៅអាស្រ័យនឹងវត្តលោក ដើម្បីគិតធ្វើសមណធម៌ ខំប្រឹងហាត់ពត់ចិត្តឱ្យរលត់ពីសេចក្ដីទុក្ខ ដែលនៅដេកត្រាំក្នុងចិត្តនេះ សូមកូនទាងអាណិតឪពុក ខំទ្រាំយកចិត្តទុកដាក់ចំពោះកិច្ចការរបស់គេកុំធ្វេសប្រហែសឡើយ ទំរាំតែស្រុកបានសាន្តត្រាណ វេលាណាឪពុកទៅយកកូនមកវិញមិនខាន ។*

*ហត្ថលេខា*

*គីម-ឡេង*

លុះអានសំបុត្រនេះចប់វេលាណា នារីនាងញ័រចំប្រប់អស់អង្គា ទ្រាំឈរនៅពុំបានក៏អង្គុយក្រោមដើមរំដួលនោះវិញ ហើយយំត្អូញត្អែររៀបរាប់ថា : ឱស្ដេចមច្ចុរាជអើយ ម្ដេចឡើយអ្នកមកឆក់យកជីវិតក្រុមគ្រួសារសាច់សារលោហិតរបស់ខ្ញុំទៅ ឥតមានត្រាប្រណីដល់ខ្លួនខ្ញុំជាស្រីផងសោះ ពីដើមខ្ញុំបានអ្នកម្ដាយជាទីពឹងផ្អែក លុះឥតអំពីម្ដាយទៅនឹកសង្ឃឹមគក់ក្ដៅពឹងផ្អែកលើបងដូចជាម្ដាយ ចុះបើលោក

ប្រាប់ឱ្យសរសេរសំបុត្រនេះផ្ញើមកជូននាង ។

ណាត្រី ‐ ម្ដេចបងស្គាល់លោកចា ? ហើយស្គាល់ដល់កន្លែងនោះទៀត បានដឹងដោយសារអ្នកណា ប្រាប់បង ?

វ៉ា ‐ កាលខ្ញុំនៅរៀនសាលាវិទ្យាល័យស៊ីសុវត្ថិ មានមួយថ្ងៃខ្ញុំបានដើរទៅផ្សារកណ្ដាល ជួនជាបានឃើញនាងឈរនៅមុខផ្ទះនោះ ចំណែកលោកអ៊ុំ ខ្ញុំបានឃើញកាលពីថ្ងៃដែលគាត់ជូននាងមកស្រុកនេះ ចាប់តាំងពីថ្ងៃនោះមកខ្ញុំចងចិត្តចាំជាប់ពុំមានភ្លេច ។

ណាត្រី ‐ ខ្ញុំអរគុណបងណាស់ហើយ កុំតែបានបង កុំអីសមខ្ញុំនឹកព្រួយទន្ទឹងមើលផ្លូវលោកចាយ៉ាងណាទៅ បងពីរបីថ្ងៃទៀតខ្ញុំសូមពឹងបងឱ្យនាំសំបុត្រមួយច្បាប់ទៅជូនចាខ្ញុំវិញ តើបានឬទេ ?

វ៉ា ‐ បាទបាន សូមនាងកុំព្រួយ បើទុកជានាងឱ្យខ្ញុំទៅត្រង់កន្លែងណា ខ្ញុំក៏ទៅជូនបានទាំងអស់ ប៉ុន្តែខ្ញុំសូមផ្ដាំ កាលណាបើនាងឃើញខ្ញុំក្រោយៗ សូមកុំឱ្យគេចវេះដូចអម្បាញ់មិញនេះទៀតណា ។

វ៉ា មានវាចាយ៉ាងដូច្នេះដល់ចប់ចុងពាក្យ អ្នកក៏ញញឹមព្រាយឡើង ។

ពេលនោះនិសាត្រដាងសំណាញ់ខ្មៅក្រាលពេញប្រថពី គឺត្រូវដល់ពេលព្រះសុរិយាលាចូលរូងស្រមោលងងឹត ប្រញាប់សំដែងឫទ្ធិលេចចេញមកភ្លាម ហាក់បីដូចជាមកបំបែកបំបាក់គូរទេ្វរគតនេះ ឆក់

យកនារីណាត្រីឱ្យបែកចេញពីទ្រូងវរ៉ា ណាត្រីនាងដើរចេញទៅៗ ទាំងស្រណោះ វរ៉ាឈរខំសំឡឹងមើលពីក្រោយខ្នងទាំងអាលៃ មិនយូរប៉ុន្មានកញ្ញាដើរឆ្ងាយទៅ ៗ ផុតពីភ្នែក វរ៉ាចាត់ ៗ ឃើញនៅតែដើមឈើដុះច្រូងច្រាងខ្មៅស្លុងៗ តាមផ្លូវដែលណាត្រីនាងដើរទៅនោះ (គួរឱ្យអាសូរណាស់) ។

# ជំពូកទី ៧

## នាងណាគ្រីផ្ញើចិញ្ចៀនតាមវរ៉ាទៅឱ្យឪពុក

ចាប់តាំងពីថ្ងៃនោះមក ណាគ្រីនាងទន្ទឹងឱ្យតែបានឱកាសទំនេរវេលាណា គិតឆ្លៀតទៅរកជួបនឹងវរ៉ាទៀត ដើម្បីសុំឱ្យជួយនាំសំបុត្រកិច្ចការទៅជូនបិតា ហើយនាងក៏នឹកក្នុងចិត្តឡើងថា តាមដោយអញសំឡឹងមើលទៅចិត្តបងវរ៉ា ច្បាស់ជាមានសេចក្ដីបេតីមេត្រីមកលើរូបអញពិតៗ ប៉ុន្តែអ្នកមិនហ៊ានស្ដីបំពានក្នុងពេលដែលអញកំពុងតែមានទុក្ខ ព្រោះអ្នកជាមនុស្សស្គាល់រាក់ជ្រៅដឹងសុខទុក្ខចេះគួរសម ពិតមែនតែរូបរាងកាយរបស់អ្នកមិនសូវល្អ ហើយជាកូនអ្នកខ្សត់ទ្រព្យសម្បត្តិពិត តែអ្នកកាន់កិរិយាមារយាទល្អត្រឹមត្រូវថ្លៃថ្នូរសំឡឹងមើលទៅគ្មានទាស់ភ្នែក ជាជាងមនុស្សដែលមានរូបរាងកាយល្អ នឹងមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ តែកាន់កិរិយាមារយាទថោកទាបដូចមានរូបសុីណាតជាភស្ដុតាង អាងតែឪពុកម្ដាយមានទ្រព្យសម្បត្តិច្រើន គិតតែទារយកមកសុីចាយសប្បាយជាមួយមិត្តអាក្រក់ ដើរលេងគ្មានលោះវេលាណា ពេលយប់ដើរទាល់ភ្លឺ ពេលថ្ងៃដេកទាល់

ល្ងាច ល្ងមដល់ពេលបាយទើបភ្ញាក់ឡើង រួចបាយហើយដើរទៅចាត់ទៀត យកយប់ធ្វើថ្ងៃ យកថ្ងៃធ្វើយប់ កាន់កិរិយាមារយាទខុសទំនងមិនត្រូវបែបបទដូចអ្នកផងទាំងពួង មនុស្សបែបនេះអញមិនប្រាថ្នាឱ្យជួបឡើយ ទោះបីមានរូបឆោមលោមពណ៌ល្អ នឹងទ្រព្យសម្បត្តិគរយ៉ាងណាក៏ដោយ ក៏សូមកុំឱ្យគិតដល់យល់ឃើញស្រមោលឱ្យសោះ សូមប្រាថ្នាជួបតែមនុស្សណាដែលមានចិត្តធម៌សប្បុរស ដឹងសុខទុក្ខគ្នា ទើបពេលក្រោយបើសិនជាមានអាសន្នអន់ក្រមកដល់ពឹងពាក់រកគ្នាបាន ។

* * *

មានសម័យថ្ងៃមួយជាថ្ងៃពេញបូណ៌មី ព្រះសូរិយាកាន់តែជ្រេទេទាបទៅ ។ តាប៉េង យាយស៊ឹម បានមូលមាត់រត់គំនិតបបួលគ្នាទៅជញ្ជូនដីចាក់បន្តធ្វើផ្លូវថ្នល់ចូលទៅវត្តដូនស ដែលស្ថាងនៅខាងក្រោយឆ្ងាយពីផ្ទះគាត់ចំនួន ២ គីឡូម៉ែត្រ ។

ចំណែកនារីណាត្រី ពេលនោះនាងកងសំពត់អាវ នឹងកាន់សាបូមួយដុំដើរសំដៅទៅកំពង់ទឹកដើម្បីទៅជម្រះកាយ ។ លុះដល់កំពង់ទឹក នាងដោះសំពត់អាវផ្លាស់ក្រម៉ាចុះពន្លិចខ្លួនត្រាំក្នុងទឹកទន្លេនោះ ហើយក៏គន់មើលទៅទិសខាងកើត ស្រាប់តែឃើញមាន

ទូកតូចមួយអុំសន្សឹមៗ សំដៅមក ទូកនោះមកកាន់តែជិត នាងនឹក ជាក់ក្នុងចិត្តថា "អ្នកអុំទូកនោះពិតជាបងវ៉ា"។ មួយសន្ទុះក្រោយមក ទូកបានចូលមកដល់កំពង់អែបជិតកន្លែងដែលនាងមុជនោះ នាងក៏ សួរទៅវ៉ា ថា : ចុះបងអុំទូកមកពីណា ?

វ៉ា - បងទើបតែឆ្លងមកពីចំការពោត ដែលនៅកោះខាង ណោះ ។

នាងគ្រាន់តែមានវាចាសួរតែប៉ុណ្ណោះ ក៏ប្រញាប់ប្រញាល់ ឡើងមកផ្លាស់ក្រម៉ា ហើយស្លៀកពាក់សំពត់អាវទៅវិញ រួចដើរទៅ ជិតវ៉ា ។

វ៉ា កំពុងតែខំអូសទូកឡើងលើគោក លុះក្រឡេកទៅឃើញ ណាត្រីដើរមកជិតអ្នកក៏ឈប់ធ្វើការ ។

ណាត្រីនាងបូតចិញ្ចៀនពេជ្រមួយវង់ពីនាងដៃ ហុចប្រគល់ឱ្យ បុរស ទើបមានពាក្យខ្សឹបៗ ថា : "ចូរបងអាណិតមេត្តាយកចិញ្ចៀន ពេជ្រមួយវង់របស់ខ្ញុំនេះទៅជូនលោកតាផង ហើយជំរាបថា : ខ្ញុំផ្តាំ ទៅឱ្យលោកយកចិញ្ចៀននេះ ទៅលក់ទុកចាយវាយចុះ ហើយសូម ឱ្យអាណិតឆាប់ៗ មកយកខ្ញុំទៅផង ព្រោះនៅទីកន្លែងនេះជាសត្រូវ របស់ខ្ញុំៗ ទ្រាំនៅមិនបានទេ ដ្បិតខ្ញុំរវល់មិនបានធ្វើជាសំបុត្រផ្ញើ ទៅជូន សូមបងកុំភ្លេចពាក្យខ្ញុំទាំងប៉ុន្មាននោះណា ណ្ហើយខ្ញុំសូមលា

បងសិនហើយ ខ្លាចក្រែងគេនិន្ទាព្រោះកន្លែងនេះ មិនមែនជាទីស្ងាត់ទេ"នាងនិយាយទាំងភិតភ័យ ហើយប្រញាប់ដើរចេញទៅ ។

ចំណែកវរ៉ា អ្នកខំយកចិត្តទុកដាក់ផ្ទៀងស្តាប់វាចារបស់នារីផ្តែផ្តាំសព្វគ្រប់តាំងពីដើមដល់ចុង ចាំបានទាំងអស់គ្មានភ្លេចមួយម៉ាត់ឡើយ កាលនារីដើរចេញផុតទៅ អ្នកជ្រើសរើសយកពាក្យទាំងប៉ុន្មានមកពិចារណាក្នុងខ្លួន ឃើញមានពាក្យមួយម៉ាត់គួរឱ្យអ្នកនឹកបារម្ភក្នុងចិត្តគឺ ពាក្យនារីថាកន្លែងនេះជាសត្រូវរបស់នាង បុរសព្រួយដោយអ្នកមានខ្លួនលួចគួចមេត្រីចំពោះលើរូបនាងពិត អ្នកនឹកថា : ពាក្យនេះសមបើនាងថាឱ្យអញទេដឹង ដ្បិតខ្លួនជាអ្នកខ្សត់ទ្រព្យធន ដូច្នេះមិនគួរសមទៅហ៊ានប្រាថ្នាគួចស្នេហាចំពោះរូបស្រីទេ ប្រៀបដូចជាសត្វជន្ទេនស្រឡាញ់តារាលើមេឃ ។ ឱអញអើយ មិនគួរហ៊ានលូកដៃទៅឈោងចាប់ ផ្កាយដែលនៅខ្ពស់ឆ្ងាយពីខ្លួនម្ល៉េះសោះ ចាប់តាំងពីត្រឹមថ្ងៃនេះតទៅ ត្រូវតែអញកាត់សេចក្តីមេត្រីស្នេហាហួសប្រមាណនេះចេញ ហើយអ្នកនឹកទៅរូបស៊ីណាតងណោះទើបគេសមរម្យ ព្រមទាំងនាងប្រហែលមានចិត្តបដិព័ទ្ធស្នេហាទៅរកគេ ព្រោះគេជាកូនអ្នកមានស្តុកស្តម្ភ សមទាំងរូបរាងគេក៏ល្អ ហើយនាងក៏មកនៅជ្រកដោយសារនឹងផ្ទះគេទៀតផង តែអ្នកពិចារណាវែងឆ្ងាយទៅនឹកឆ្ងល់ថា: បើសិនជានាងមានសេចក្តី

ស្នេហាចំពោះស៊ីណាតមែន ម្ដេចក៏មកពឹងរូបអញឱ្យនាំសេចក្ដីនេះទៅជំរាបបិតានាងទេវិញ ។

មួយវិញទៀត ពិតតែអញមានសេចក្ដីគួចមេត្រីស្នេហាទៅលើរូបនាងមែនហើយ ប៉ុន្តែអញមិនដែលមានវាចាមួយម៉ាត់មិនជាទីគាប់ចិត្តអ្វីដល់នាងក៏ទេដែរ ” ។ បុរសអ្នកត្រិះរិះគិតដូច្នោះហើយមានចិត្តរាវែកកាត់មិនដាច់ស្រេច ម្ដងថាពាក្យនេះពិតជានាងថាមកឱ្យខ្លួន ម្ដងនឹកថាពាក្យនេះទំនងជានាងមិនមែនថាឱ្យខ្លួនទេ កាលបើអ្នកពិចារណាទៅមិនដាច់ស្រេចក្នុងចិត្តអ្នក ក៏ឈានជើងដើរទៅទាំងងឹតមុខសំដៅទៅផ្ទះ ប៉ុន្តែក្នុងចិត្តនឹកថាយប់នេះខែភ្លឺ អញទៅជួយលើកដីចាក់ថ្នល់ចូលវត្តនឹងគេ ដល់ព្រឹកស្អែកនឹងធ្វើដំណើរទៅភ្នំពេញ ។

LIBRARY
BUDDHIST INSTITUTE

# ជំពូកទី ៨

## ណាត្រីជួយទរ៉ា ហើយក៏បានកើតបានជាស្នេហា

ចំណែកស៊ីណាត កាលបើសេចក្តីប្រាថ្នារបស់ខ្លួនមិនបានសម្រេច ដោយណាត្រីនាងធ្វើសោះអង្គើយ តោះតើយ មិនព្រមតបសេចក្តីមេត្រីមករកដូច្នោះហើយ ស៊ីណាតចេះតែនឹកក្តៅក្រហល់ក្រហាយអន្ទះអន្ទែងពន់ប្រមាណ ទទួលយប់នោះមានមនុស្សមកប្រាប់ដំណឹងសព្វគ្រប់អំពីនារីទៅជួបនិយាយនឹងវរ៉ា ។

ស៊ីណាតកាលបើបានដំណឹងនេះ ចូលមកដល់ត្រចៀកកាលណាក៏ស្ទុះស្ទាយ៉ាងរហ័ស ទៅបើកទូយកកាំបិតស្នៀតមួយយ៉ាងមុតមកសៀតត្រង់ចង្កេះ រួចទៅទាញយកដបស្រាមកចាក់ផឹក១ ដើម្បីចង់ពង្រីកចិត្តឱ្យក្លាហាន លុះមិនយូរប៉ុន្មានក៏គិតក្នុងចិត្តឡើងថា : អញនឹងទៅបបួលមិត្តភក្តិអញ ២-៣នាក់ ក្នុងពេលឥឡូវនេះតាមទៅប្រហារជីវិតអាអ្នកក្រនេះចេញ ហើយកាត់យកតែក្បាលមកបង្ហាញឱ្យនាងឃើញស្នាដៃ គិតដូច្នោះហើយក៏កាន់ដបស្រាតាមខ្លួនដើរចេញមកក្រៅសំដៅមករកនាងកំពុងតែអង្គុយលើរានទៅមុខផ្ទះ ។

គាប់ជួនជាក្នុងថ្ងៃនឹង តាយាយមិនទៅផ្ទះស៊ីណាតឃើញស្ងាត់ដូច្នោះ ក៏និយាយទៅរកនាងដោយពាក្យគ្រគោះបោះបោកឥតកោតញញើតថា : ។

ស៊ីណាត - ណាត្រីចុះហេតុដូចម្តេចបានជានាងទៅមានសេចក្តីស្នេហានឹងអាវ៉ា ដែលជាមនុស្សអ្នកក្ររកតែអ្វីស៊ីគ្មានទៅ វិញដូចជាខ្លួនបងនាងដឹងស្រាប់ហើយប្រាក់មិនខ្វះចាយ បាយមិនខ្វះស៊ីមានផ្ទះថ្មធំប៉ុនគ្រឹះសម្រាប់ឱ្យនាងនៅទៀត ម្តេចបងគ្រាន់តែនិយាយរាប់រកផងនាងសំដែងអាការៈសោះអង្គើយ ធ្វើហាក់ដូចជាមិនស្គាល់គ្នាដូច្នេះ ចាំមើលអាវ៉ាគង់តែនឹងដឹងដៃគ្នាក្នុងយប់នេះមិនខាន ឥឡូវនេះបងទៅហៅពួកម៉ាកតាមទៅសម្លាប់កាត់យកក្បាលវាមកបង្ហាញឱ្យឃើញស្នាដៃម្តង សោះនាងមាក់ងាយបងតទៅទៀត ថាដូច្នេះហើយស៊ីណាតក៏កាន់ដបស្រាដើរទ្រេតទ្រោតកាត់ចំការដំណាំខាងក្រោយផ្ទះទៅ ។

ណាត្រី នាងភ័យញ័ររន្ធត់សព្វសពាង្គកាយ ហាមាត់និយាយពាក្យម្តេចក៏ពុំទាន់ស៊ីណាត ដើរចេញផុតទៅ នាងនឹកក្នុងចិត្តឡើងថា " ឱបងវ៉ាអើយចុះបងដើរទៅណាទាំងរាត្រីថ្ងៃនេះ " ប្រហែលជាបងទៅលើកដីចាក់ថ្នល់ចូលទៅវត្តជូនសនោះហើយ ព្រោះថ្ងៃនេះជាថ្ងៃពេញបូណ៌មី អ្នកស្រុកគេតែងនាំគ្នាទៅខំយកកុសលរៀង១ ខ្លួន

" ឱបងអើយ ! បងខំប្រឹងទៅធ្វើការកុសល អ្នកគ្មានដឹងថា ពួកមនុស្សពាលទាំងនេះ វានាំគ្នាតាមទៅបម្រុងប្រហារជីវិតអ្នកសោះឱលោកអើយ ! មិនដឹងជាទៅពឹងអ្នកឯណានាំសេចក្តីនេះទៅប្រាប់បងវ៉ា ឱ្យអ្នកបានដឹងខ្លួន កាលបើនាងកំពុងតែនឹកព្រួយបារម្ភដល់ទៅតូគាប់ចិត្តជាខ្លាំង ហេងហាងមិនដឹងជាទៅរកពឹងអ្នកណា ទើបនាងងើយមើលទៅលើឃើញព្រះចន្ទរះពេញវង់ មានពន្លឺរស្មីភ្លឺត្រចះត្រចង់ហើយមានផ្កាយតូច-ធំរះអមព្រោងព្រាតលើនភាល័យ គួរជាទីមនោរម្យពន់ប្រមាណ ទើបណារត្រីលើកដៃបន្ទូល ហើយពោលក្នុងមាត់ខ្សិបៗ ថា " ឱព្រះចន្ទអើយសូមលោកអាណិតមេត្តាជួយនាំដំណឹងអាក្រក់នេះទៅប្រាប់ដល់បងវ៉ាផង" ។

ព្រះចន្ទធ្វើព្រងើយកន្តើយ ដូចជាមិនបានឮសូរសំឡេងស្រីបន្តិចបន្តួចសោះឡើយ ម៉្លោះហើយនាងក៏រេគំនិតគិតជាថ្មីឡើងទៀតថា "ខ្លួនអញអើយ ! មានតែទីពឹងខ្លួនឯងហើយទើបបានកើត ឥឡូវនេះគិតទៅតាមមនុស្សនេះ រកបញ្ហានិយាយដោះសាបោកបញ្ឆោតឱ្យតែពីខាងកើតការកុំឱ្យវាទៅប្រាថ្នាប្រហារជីវិតបងវ៉ាបាន ។ នាងគិតឃើញដូច្នោះហើយ ទើបស្រែកហៅផេងរិនជាក្មួយមកប្រាប់ថា "ចូរឯងទៅហៅពូម៉ៅ (ជើងឈ្នួល) នៅខាងក្រោយផ្ទះមកនៅជាមួយណា ម៉ាក់មីងមានការទៅក្រោយមួយភ្លែត កាលបើនាងផ្តាំ

ជេងរិនស្រេចហើយ ក៏ប្រញាប់ប្រញាល់ចេញដើរតាមក្រោយផ្ទះ កាត់អស់ចំការព្រៃព្រឹក្សាទាំងរាត្រីស្ងាត់សូន្យឈឹង នារីណាត្រី ខំដើរស្រូតយ៉ាងលឿន តែក្នុងចិត្តភិតភ័យឥតឧបមា ដោយខ្លាចសព្ទសំឡេងមាត់សត្វនានា មានមៀម ទីទុយជាដើមយូរៗ ឮសូរមាត់វាស្រែកយំម្តងៗ នារីព្រឹក្សាលភ័យញ័រចំប្រប់សព្វសពាង្គកាយ ប៉ុន្តែដោយចិត្តគិតអាណិតដល់ទៅគូជាខ្លាំង ទើបប្រថុយប្រាណសុខចិត្តប្តូរជីវិតក្នុងគ្រានេះស៊ូត្រដេវត្រដរដើរតទៅទៀត លុះយូរបន្តិចមកនាងបានដើរទៅដល់ចំការពោត ស្រាប់តែឮសូរសំឡេងមនុស្សនិយាយរ៉ូងរ៉ាងនាងផ្ទៀងត្រចៀកស្តាប់ស្គាល់ច្បាស់ជាសំឡេង ស៊ីណាត ហើយនាងគេចខ្លួនចូលទៅពួនក្រោមដើមពោតដែលដុះស៊ុបទ្រុប ដើម្បីចាំលបស្តាប់អ្នកទាំងនោះ តើនិយាយការអ្វីខ្លះ ស្រាប់តែឮសូរពាក្យស៊ីណាតនិយាយទៅមិត្តភ័ក្តិថា : រើយពួកកនយើងចែកផ្លូវគ្នា អាជេងទៅចាំទិសខាងលិច អាមើនទៅចាំទិសខាងកើត ចំណែកអញនៅចាំកន្លែងហ្នឹង កាលបើអ្នកណាឃើញវាដើរមកដល់ ត្រូវយើងឱ្យសញ្ញាគ្នានឹងសម្លេងហួចតែឮសូរហួចយើង ត្រូវទៅលបចាក់សម្លាប់វាឱ្យក្ស័យតែម្តង ។

ណាត្រី កាលបើនាងស្តាប់ សូរស៊ីណាតហៅឈ្មោះមិត្តគិតគ្នាយ៉ាងសម្ងៀមដូច្នោះ នាងក៏ចងចិត្តចាំជាប់ឈ្មោះមិត្តស៊ីណាតទាំងពីរ

នាក់នោះឥតភ្លេច ។ លុះពួកនោះចេញបែកគ្នាទៅ តាមផ្លូវរៀងៗខ្លួនទៅ នាងក៏ដើរសសៀរចូលមកជិតស៊ីណាត ហើយនិយាយថា :

យីបង ! អម្បាញ់មិញនេះថា មានអ្នកណានិយាយរឿងអំពីខ្ញុំប្រាប់បង ? បានជាបងខឹងនឹងខ្ញុំ ? ហើយឥឡូវបងមកកន្លែងនេះធ្វើអ្វីទាំងយប់ថ្មើរហ្នឹង ? នាងនិយាយបញ្ចេញសំឡេងយ៉ាងទន់ភ្លន់ ហើយធ្វើទឹកមុខរីករាយញញឹមស្រស់ប្រិមប្រិយ តាមពន្លឺរស្មីនៃព្រះច័ន្ទ ។

ស៊ីណាត កាលបើបានឃើញរូបស្រី ដែលជាទីប្តូរផ្តាច់ជីវិតរបស់ខ្លួនមកដល់ចំពោះមុខ ថែមទាំងឮសូរសម្លេងដ៏ពិរោះស្មោះក្បាយដូចជាសូរតន្ត្រី ក្នុងចិត្តនឹកត្រេកអរឥតឧបមា ហាក់ដូចជាបុប្ផាក្រពុំមានក្លិនក្រអូបយ៉ាងអស្ចារ្យ ដែលអណ្តែតត្រសែតលើនភាល័យធ្លាក់ចុះមកចំលើខ្លួនក្នុងវេលាហ្នឹង សេចក្តីខឹងគំគួនទាំងប៉ុន្មាន ដែលដេកត្រាំនៅក្នុងសន្តានរបស់យុវជននេះ ក៏រសាយចេញឆ្ងាយពីក្នុងកាយភ្លាម ទើបបញ្ចេញសំដីបែបរាងប្រច័ណ្ឌឡើងថា ចុះក្រែងអូនឯងទៅស្រឡាញ់អាវ៉ាហើយឬ ?

ណាត្រី - អើចុះបងឮពីណាមក ? "នាងសួរធ្វើបែបរាងខឹង"

ស៊ីណាត - បងឮអាថែមក្មេងលោកវ៉ានិយាយប្រាប់បង ។

ណាត្រី - ម្តេចក៏បងជឿសំដីក្មេងតូចកូនសិស្សលោកដូច្នេះ ?

វានិយាយពាក្យផ្ដេសផ្ដាសទេតើ ព្រោះខ្ញុំពុំដែលស្គាល់សោះ រូបគាត់ហ្នឹង សូម្បីតែឈ្មោះក៏ពុំដែលបានឮសូរផង ពុទ្ធោអើយ ម្ដេចបងទៅខឹងនឹងគេទទេៗ ដូច្នេះ ។

ពេលនោះ ស៊ីណាតភ្លេចនឹកពាក្យក្មេង ដែលចាស់ៗ ធ្លាប់យកជាការថាពាក្យពិត ទៅជាគិតថាពាក្យក្មេងជាពាក្យព្រើល ហើយនិយាយតបមកនាងវិញថា " អើមែនហើយអូន ! ក្មេងវាច្រើនតែព្រើលៗ និយាយការផ្ដេសផ្ដាសមែនហើយ ប៉ុន្តែបើប្អូនចិត្តស្មោះត្រង់នឹងបងមែន សូមនាងយកចិញ្ចៀនមកបង្ហាញបងមើល ហើយបងសូមអង្វរចិត្តនាង ចាប់តាំងពីត្រឹមថ្ងៃនេះទៅកុំឱ្យអូនដើរចេញទៅណាមកណា បងគិតសូមឱ្យឪពុកម្ដាយបងទៅស្ដីដណ្ដឹងស្រីរៀបអាពាហ៍ពិពាហ៍ជាគូស្វាមីភរិយា យើងនៅរួមសុខទុក្ខជាមួយគ្នាទាល់តែអស់ជីវិតរៀងៗ ខ្លួន ។ ស៊ីណាតនិយាយទាំងសំដីគ្រលរដោយផឹកស្រាច្រើនពេក ដំណើរសោតក៏ឈរមិននឹងនួនចេះតែទ្រេតទ្រោតចុះឡើង លុះមានវាចាគ្រាន់តែផុតពីមាត់ក៏រលំខ្លួនដួលស្រូសប្រាសដេកស្ដូកទៅលើព្រះធរណី ។ ពេលនោះស្រាប់តែឮសូរសញ្ញាសម្លេងហូចធ្វេចៗ ដល់នាងនឹកក្ដុកក្នុងចិត្តហើយ គិតថាច្បាស់ជាបងវរ៉ាមកដល់ហើយ ត្រូវតែអញតាំងចិត្តអង់អាចក្លាហានស្រែកគម្រាមឱ្យ អាដែងអស់នេះវាដឹងខ្លួនហើយនាងស្រែកភ្លាម ។ ឈ្មោះ

ផង ឈ្មោះមេីនអ្នកហួចឱ្យសញ្ញា ប្រាថ្នាសម្លាប់ជីវិតគេឬ អ្នកទាំងអស់គ្នាតោងតែមកជិតយេីង ។ នឹងថ្លែងសេចក្តីដ៏សំខាន់មានប្រយោជន៍មួយប្រាប់ដល់អ្នក ។ ពួកអ្នកអស់នោះកាលបេីឮសម្លេងស្រីស្រែកហៅចំមកឈ្មោះខ្លួនដូច្នោះហេីយ ក៏នឹងភ័យស្រឡាំងកាំងដេីរតម្រង់មករកនាងណាត្រី ក៏មានវាចាឡេីងថា ៖ ចូរអ្នកទាំងពីរនាក់ចាំស្តាប់ខ្ញុំនិយាយប្រាប់ អ្នកមេីលរូបស៊ីណាតដែលជាមនុស្សគម្រក់ អាងតែស្រាយកមកធ្វេីជាមុខមាត់ ឥឡូវនេះផឹកជ្រុលហួសប្រមាណពេកទៅទាល់តែចង្អោរដួលដេកស្តឹងស្តូកលេីដី គួរឱ្យអ្នកណាដែលមេីលឃេីញនឹកខ្ពេីមខ្ពេីមពន់ប្រមាណ មនុស្សអ្វីក៏ប្រព្រឹត្តកិរិយាមារយាទថោកជាងសត្វតិរច្ឆានទៅទៀត ចូរអ្នកពិចារណាគិតមេីល បេីអ្នកប្រព្រឹត្តិធ្វេីតាមបង្គាប់មនុស្សនេះ អ្នកមុខតែត្រូវទោសឧក្រិដ្ឋមិនខាន លុះស្លាប់ទៅកម្មអកុសលនោះ នាំឱ្យធ្លាក់ទៅសោយទុក្ខវេទនាក្នុងនរកទៀត ។

ពួកអ្នកទាំងពីរនាក់នោះ កាលបេីស្តាប់ស័ព្ទសំដីនារីនិយាយដាស់តឿនដូច្នោះក៏ពោលឡេីងព្រមគ្នាថា ៖ ខ្ញុំសុំអរគុណនាងចាប់ពីត្រឹមថ្ងៃនេះតរទៅ ខ្ញុំលែងហ៊ានប្រព្រឹត្តិបទបែបនេះទៀតហេីយ លុះនិយាយរួចហេីយក៏ថយខ្លួនពីនាងដេីរចេញទៅ ។

ចំណែកវរ៉ា អ្នកពួនសម្ងំខ្លួនក្បែរគុម្ពឫស្សីមួយគុម្ពដែលនៅ

ជិតនោះ ខំផ្ទៀងស្ដាប់សំឡេងនាង ដឹងអស់កិច្ចការសព្វសារពើ ។

ណាត្រី កាលដែលពួកខ្មាំងទាំងនោះចេញផុតទៅ នាងខំគយគន់រំពៃរកមើលវ៉ា ស្រាប់តែមួយសន្ទុះឃើញវ៉ាដើរស្ទុងមកនាងស្ទុះទៅរក ។ ពេលនេះហើយដែលវ៉ាហ៊ានលូកដៃទៅចាប់ដៃណាត្រី ហើយបបួលគ្នាទៅអង្គុយក្រោមដើមស្វាយមួយ ដែលមានស្លឹកត្រសាយត្រសុំសាខា គន់មើលទៅព្រះចន្ទ្រាអណ្តែតត្រសែតឡើងខ្ពស់ជិតចំពាក់កណ្តាលមេឃា ។

ណាត្រី - នាងនិយាយទៅកាន់វ៉ាថា : បងអើយតពីថ្ងៃនេះទៅប្រហែលជាយើងខានឃើញមុខគ្នាទៀតហើយ ព្រោះប្អូនសព្វថ្ងៃនៅក្រោមអំណាចអាមនុស្សចិត្តខ្មៅនេះ នាងស្រក់ទឹកភ្នែកហូរសស្រាក់ ។

វ៉ា - ឱអូនអើយ ! សំយើងព្រាត់ប្រាសគ្នាមិនខាន កម្មអកុសលអ្វីក្រាសម្ល៉េះមកកាត់បំបែកភ្ញាម១ ។ ស៊ីណាត អានេះចិត្តខ្មៅដល់ម្ល៉ឹងហ្ន៎ ។

ណាត្រី - អម្បាញ់មិញនេះវានិយាយថា គិតឱ្យឪពុកម្ដាយវាទៅដណ្ដឹងរូបខ្ញុំ ហើយសួររកចិញ្ចៀនទៀតផង បើដូច្នេះសូមបងឱ្យចិញ្ចៀននោះមកខ្ញុំវិញ ហើយកុំទៅជំរាបដំណឹងលោកប៉ាឱ្យជ្រាបណា ការទាំងប៉ុន្មានដែលខ្ញុំបានជំរាបបងនោះ ខ្លាចក្រែងគាត់

អញ្ជើញមក សមគេគិតនិយាយស្ដីរណ្ដឹងខ្ញុំមិនខាន ។ ខ្ញុំចចិត្ត លោកប៉ាយល់ព្រមឱ្យខ្ញុំទៅគេ ព្រោះគេមានទ្រព្យសម្បត្តិច្រើន ម្យ៉ាងទៀត គេជាមិត្តភក្ដិរបស់គាត់ស្រាប់ផង ។

វ៉ា - បើលោកប៉ាយល់ព្រមឱ្យទៅគេ សូមអូននាងស្ដាប់ពាក្យ អ្នកមានគុណទៅចុះ ព្រោះខ្លួនបងជាអ្នកក្រមិនអាចជួយយោងមុខ មាត់អូនឱ្យខ្ពង់ខ្ពស់ដូចគេបានឡើយ ។ អ្នកថាដូច្នោះហើយលូកយក ចិញ្ចៀនពីក្នុងហោប៉ៅហុចឱ្យទៅនាង ទឹកភ្នែកហូរចេញមកព្រិចៗ ។

ណាត្រី - ចាំសទេបងកុំមានប្រសាសន៍ដូច្នេះ ប្អូនមិនសប្បាយ ចិត្តនឹងស្ដាប់ពាក្យអ្នកទេ ប្អូនសូមសច្ចាឱ្យបងជឿជាក់ក្នុងចិត្តប្អូនថា កើតមកខ្លួនជាស្រីមានចិត្តបេតីចំពោះលើរូបបងតែម្នាក់ បើក្រៅ អំពីរូបបងប្អូនត្រូវតែជៀសឱ្យផុត បើជៀសមិនផុតទេប្អូនមុខជាសូម លាបងក្សិណក្ស័យជីពជន្មទៅកាន់បរលោកនាយ ទើបប្រសើរជាង សឹងមានព្រះចន្ទធ្វើជាសាក្សី ។ នាងនិយាយទាំងខ្សឹកខ្សួលទឹកភ្នែក ចេញមកប្រោកៗលើសដើម ។

វ៉ាអ្នកក៏កាន់តែណែនដើមក រកតែហាមាត់និយាយទៅវិញ មិនរួច ហើយចាប់ដៃនារីយកមកផ្ដោបនឹងទ្រូងរបស់អ្នក ។

ស្រាប់តែឮមាត់តាប៉េង នឹងពូម៉ៅប្រកួកហៅឈ្មោះនាង ស្រែកយ៉ាងខ្លាំងៗផ្អើលអស់ទាំងសត្វ បក្សាបក្សីក្នុងកណ្ដាលរាត្រី

ស្ងាត់ស្ងួន្យឈឹង ។

វ៉ា អ្នកក៏ត្រូវបែកឃ្លាតចេញពីណាត្រីក្នុងពេលនោះ ។

ណាត្រី នាងដើរសំដៅមករកតាប៉េង ហើយចង្អុលប្រាប់កន្លែងដែលស៊ីណាតធីកស្រាស្រវឹងដួលដេកស្តូកស្តឹងនោះ ។

តាប៉េងក៏ប្រើឈ្នួលឱ្យលីស៊ីណាតដាក់លើស្នា ហើយហៅនារីដើរសំដៅមកផ្ទះ ។

# ជំពូកទី ៩

## ដោយជម្ងឺអាសន្នរោគ ណារ៉ុត្រូវគេបោះបង់ចោល

ចាប់តាំងពីថ្ងៃនោះមក នារីនាងក៏ទៅជានៅក្រោមអំណាចស៊ីណាតគ្រប់គ្រង មិនឱ្យដើរទៅណាមកណាបាន ប្រៀបដូចជាសត្វជាប់ក្នុងទ្រុងគេ ។

ចំណែកខាងស៊ីណាត រង់ចាំឱ្យតែបានដំណឹងថា បិតានាងនៅឯណា គិតឱ្យមាតាបិតាខ្លួនចូលទៅស្ដីដណ្ដឹង ។ នារីកាលបើបានដឹងទឹកចិត្តស៊ីណាតដូច្នោះហើយ នាងចេះតែមានសេចក្ដីនឹកព្រួយបារម្ភគ្រប់ពេលវេលា មុខមិនដែលរីក បាយពុំសូវបាន ពេលយប់និទ្រាពុំហ៊ានឱ្យលក់ស្កប់ស្កល់ ។ ក្នុងចិត្តតែងតែនឹកព្រួយខ្លាចស៊ីណាត ក្រែងហ៊ានរំលោភបំពានប៉ះពាល់ដល់រូបកាយដោយការពុំគប្បី រាត្រីមួយនាងនឹកថា ឱលោកអ្នកមានគុណរបស់កូនអើយ ! ម្ដេចឡើយលោកយកកូនមកបោះបង់ចោលមិននឹកនា ហាក់ដូចជាយកកូនមកផាត់បំណុលឱ្យគេយ៉ាងដូច្នេះ ឬមួយលោកគិតប្រាថ្នាឱ្យកូនទៅរួបស៊ីណាតទេដឹងអើយ បានជាលោកធ្វើព្រងើយកន្តើយ គ្មាន

នឹកនាមកដល់កូនបន្តិចបន្តួចសោះឡើយ ។ "ឱរូបអញអើយ ! កម្មអ្វីក្រាសម្ល៉េះ ឱ្យចេះតែទទួលទុក្ខច្រើនលើកច្រើនគ្រាពុំចេះបានស្បើយសោះ តើតទៅអនាគតអញនឹងមានបុណ្យព្រេងវាស្នាដែរឬទេ?"។

ពេលនោះយប់យន់កាន់តែជ្រៅណាស់ទៅហើយ យូរ ៗ សម្លេងតម្លូញរបស់ឆ្កែ ឮមកដល់ត្រចៀកនាងម្ដងៗ សម្លេងលលកខ្មោច ចង្រិតជែកស្រែកបន្តគ្នាយ៉ាងស្រួយគ្មានចេះឈប់ឈរ បំណែកក្លិនបុប្ផាសនានា មានរំដួលចន្ទ ម្លិះរួត ម្លិះលា ចម្ប៉ាក្ដាំងងា ដែលផ្ញើជីវិតរស់នៅជុំវិញផ្ទះថ្មីនេះ ក៏ដណ្ដើមគ្នាបញ្ចើរក្លិនលេងតាមវាយោជំនោរវាយោក៏ដឹកនាំក្លិនបុប្ផាបញ្ចូលតាមចន្លោះបង្អួចតូចមួយ នៅក្នុងបន្ទប់ដំណេករបស់នាង ។

ណាត្រី កាលបើបានស្រូបពិដោឈ្ងុយឈ្ងុបទាំងនេះ ទឹកភ្នែកក៏ហូរស្រក់ច្រោកៗ ជោកខ្នើយដែលនាងកើយ ។ នារីក្រោកចាកអំពីដំណេកម្ដីម្ដាមកអង្គុយលើកៅអី នៅមុខតុតូចមួយដែលមានសៀវភៅពីរ-បី ទឹកខ្មៅនឹងដងចាក់ា ព្រមទាំងពន្លឺចង្កៀងប្រេងកាតប្លុងៗ នៅលើនោះ ទើបនាងនឹកថា : "សេចក្ដីទុក្ខរបស់អញអើយ ! សមជាបែកទ្រូងស្លាប់ទេដឹង ? ដោយគ្មានញាតិរបស់អញឯណាម្នាក់ដែលល្មមគួរទុកចិត្ត ដើម្បីពោលទុក្ខទាំងនេះប្រាប់គ្រាន់បានធូរទ្រូងផង បើដូច្នេះមានតែអញកត់ចារសេចក្ដីទុកនៅលើក្រដាសក្រែង

បានស្មើយ សោះចុកណែនឱរាពេក" ទើបនាងចាប់ផងប៉ាកាបង្ហូរទឹកខ្មៅទៅលើក្រដាសសមួយសន្លឹក មានសេចក្តីថា :

*ឱ ! ផ្ការំដួលអើយ ! ខ្ញុំពុំភ្លេចអ្នកទេ កាលដែលខ្ញុំបានជួបនឹងអ្នកនៅទីវាលនៃពពួកអ្នកគង្វាលគោនោះ ។*

*ចន្ទអើយ ! ភ្លឺនអ្នកម្តេចខ្សោយជាងគេម៉្លេះ ? តើអ្នកនៅនាស្ថានឯណា ? តែចិត្តរបស់ខ្ញុំនឹកអ្នកគ្មានឈប់ឈរទេ ពេលដែលអ្នកចិតនាលើអាកាស រស្មីបំភ្លឺចាំងមកលើដើមស្វាយ នៅក្នុងចំការពោតនូវកណ្តាលរាត្រីស្ងាត់នោះ . . . . . .*

*ចំណែកបុប្ផានានា ចម្ប៉ាក្តាំងងា ក្នុងគ្រានេះពិតមែនតែខ្លួនខ្ញុំនៅឆ្ងាយអំពីអ្នក តែចិត្តខ្ញុំសុំប្តេជ្ញាថា : ភ្លឺនក្រអូបវិសេសរបស់អ្នកយ៉ាងណា សេចក្តីស្នេហារបស់ខ្ញុំក៏មានខ្លឹមសារខ្លាំងក្លាស្មើនឹងអ្នកដែរ ។*

*បើទុកណាជាអ្នកណាមួយ ទៅបេះប្រឡេះឱ្យអស់រលីងចេញពីដើម មិនយូរប៉ុន្មានគង់អ្នកពន្លក រីកស្គុះស្គាយឡើងមកទៀត មិនបេះអស់ទេ ក្រែងតែអ្នកដាច់ដួងកែវជីវិត ទើបបានផុតរូបនឹងចិត្តរបស់ខ្ញុំក៏ដូចជាអ្នកដែរ ។*

*ហត្ថលេខា*

*ណាត្រី*

កាលបើនាងប្រព្រឹត្តិសេចក្តីទុក្ខសង្រេងសង្រៃយ៉ាងដូច្នេះ យូរថ្ងៃទៅខ្លួននាងក៏ស្គមនៅស្បែកនឹងឆ្អឹង សាច់ឡើងស្លេកស្លាំង មុខឡើងជ្រុង មើលទៅឃើញអាក្រក់ខុសប្លែកឆ្ងាយជាងពីដើម ។

ស៊ីណាតឃើញនាងមានរូបរាងអាក្រក់ដូច្នោះ យុវជននេះក៏បែកចិត្តរីគំនិតផ្លាស់ជាថ្មីឡើងថា : " នារីនេះមានរូបរាងអាក្រក់ណាស់ទេតើ សម្បត្តិទ្រព្យសោតក៏គ្មាន សាត់តគ្រាត់មកតែខ្លួនទទេប្រវេប្រវាមកនៅដោយសារនឹងផ្ទះអញ គិតមើលទៅមិនសមរម្យនឹងរូបព្រមទាំងធនធានរបស់អញឡើយ បើដូច្នោះតាំងពីថ្ងៃនេះទៅអញមិនត្រូវវិវរចងចិត្តមេត្រីចំពោះស្រីនេះទៀតទេ ចាំដល់ថ្ងៃណាសូមឱ្យឪពុកម្តាយអញទៅនិយាយស្តីដណ្តឹងកូនក្រមុំគេ ដែលជាអ្នកមានស្តុកស្តម្ភនៅជិតផ្សារឯណោះវិញ ទើបបានសមសួនថ្កុំថ្កើងល្អមសមភាពរបស់អញ.......................

.................................

* * *

គណៈនេះស្ទើរតែគ្រប់អាណាខែត្រកម្ពុជរដ្ឋ ត្រូវទទួលគ្រោះកំណាចយ៉ាងសម្បើមម្តងទៀត គឺអាសន្នរោគដែលមានឫទ្ធិដ៏ខ្លាំងក្លាតែងធ្វើឱ្យសត្វលោកញាប់ញ័ររន្ធត់ តាំងចាប់កាន់នៅកណ្តៀវសផ្ការ

ដើរច្រូតកាត់ជីវិតមនុស្សសឹងតែគ្រប់ទីតំបន់ ។

នៅក្នុងភូមិនិមួយៗ គេពុំឃើញអ្នកនិគមជនបទស្វែងរកប្រកបកិច្ចការរហេតរហូតដូចប្រក្រតីឡើយ ហើយអ្នកទាំងឡាយនេះមានកិរិយាទឹកមុខក្រៀមក្រំស្រពោនជាប់ជានិច្ច និយាយស៊ើបសួរដំណឹងកាន់គ្នាទៅវិញទៅមក ដោយខ្សឹបខ្សាវមិនហ៊ានទាំងបញ្ចេញឈ្មោះជម្ងឺនេះផង ។

នៅមុខផ្ទះខ្លះគេយកផ្ទាំងដី ក្រឡា ឬក្តម មកគូរវាសជាមុខយក្សអាក្រក់មើលក្រៃលែង ដោយកំបោរស ហើយផ្អក់នៅរបងដាក់ព្យួរនៅមែកឈើ អ្នកខ្លះយកកំបោរនេះមកគូសខ្វែងជាកាកបាទនៅគ្រប់សសរផ្ទះរបស់គេ ការធ្វើដូច្នេះដើម្បីបញ្ចៀសខ្មោចបីសាចដ៏កំណាច ដែលវាដើរចាចមេក្រម៉ុនោះ ។

លុះដល់ពេលរាត្រី មកគ្របស្លុបលើផ្ទៃផែនដីកាលណាហើយ គេនាំគ្នាបិទទ្វារសម្ងំគ្រប់ ៗ អាត្មានៅក្នុងផ្ទះ ម្ល៉ោះហើយភូមិទាំងឡាយក៏ស្ងាត់ស្ងៀមឈឹង ឮតែសម្លេងនៃសត្វតូចល្អិត វាស្រែកកញ្ឆ្រៀវបញ្ចេញមកពីក្នុងគុម្ពស្មៅ ជូនកាលសម្រែកខ្វែងស្រាកស្រែកខ្វាក-ខ្វាកឡើង នាំឱ្យមនុស្សរឹងរិតតែភ័យតក្កមាឡើង ។

អ្នកខ្លះស្រមៃ ឮក្រោកក្រាកបីដូចជាគេយកវត្ថុរឹង ប្រហែលសិលាមកជុះនៅពាងទឹកជិតក្បែរផ្ទះ ខ្លះទៀតហាក់ដូចជាឮសូរ

សម្លេងមាត់មនុស្ស ស្រែកហៅរកគ្រវ១ ឡើង ។

ស្ងរស័ព្ទសម្លេងទាំងនេះហើយ ដែលអ្នកស្រុកធ្លាប់សំគាល់ថា ជាបុព្វហេតុនៃសេចក្ដីវិនាស នឹងមានមកដល់នរណាមិនខាន .....

. . . . . . . . . . . . . . . . . . . . . . . . . . . . . . .

លុះព្រឹកព្រលឹម ដំណឹងអាក្រក់មួយព្វមកដល់ភ្នាម ឱ ! លោកអ្នក ចំណាំរបស់អ្នកស្រុកបែបខាងលើនេះត្រូវចំដូចគេបានដៅទុកណាស់ គឺនៅពេលនេះហើយដែលគេដឹងថា មានបុរសម្នាក់នៅក្នុងភូមិនេះទទួលអនិច្ចកម្មក្នុងយប់នោះ ។

ទោះមានឱសថសាកសិទ្ធិ ឬមន្តអាគមពូកែបែបណាក៏កម្រនឹងផ្ដាញ់ផ្ដាលជម្ងឺនេះឈ្នះឡើយ ជូនកាលវាបំផ្លាញជីវិតមនុស្សអស់មួយគ្រួសារ១ ក៏សឹងមាន ទាល់តែមានអ្នកខ្លះអត់ទ្រាំពុំបានសុខចិត្តរត់ចោលភូមិស្ថានដោយសារខ្លាចជម្ងឺឆ្លងមកដល់ខ្លួន អ្នកខ្លះទៀតខំបន់ស្រន់ដល់ទេវតា អារុក្ខអារក្ខ នឹងអ្នកតាផងទាំងពួង ដើម្បីសូមឱ្យជួយស្រោចស្រង់អាយុជីវិត ឱ្យបានឆ្លងផុតពីអសន្នកម្មនេះ ។

ក្នុងពេលដែលគេកំពុងភិតភ័យនោះ នាងណាត្រីស្រាប់តែមានជម្ងឺមួយមកចាប់ បង្កកើតក្នុងរាងកាយរបស់នាង ស្រដៀងនឹងរោគដែលកើតថ្មីនេះដែរ ។

តាប៉េង យាយស៊ឹម មានសេចក្ដីភិតភ័យជាខ្លាំងខំរត់ប្រញាប់រកគ្រូហួមកដាក់ថ្នាំភ្លាម ប៉ុន្តែជម្ងឺនោះមិនបានស្រាកស្រាន្តសោះឡើយ រឹងរិតតែធ្ងន់ឡើងៗលើសដើម នារីក៏លែងដឹងខ្លួនប្រាណគ្រូទាំងប៉ុន្មានក៏រត់ចោលអស់ ។

លុះដល់ពេលល្ងាច ស៊ីណាតត្រឡប់មកពីដើរលេងវិញ តាប៉េងយាយស៊ឹមឃើញកូនមកដល់ ក៏ស្ទុះទៅនិយាយខ្សឹបៗប្រាប់ថា : ណាត្រីមានកើតជម្ងឺហើយ នាងចាប់ឈឺតាំងពីយប់មិញ រង់ចាំតែកូនមកនិងគឹតគ្នាព្រោះនាងកាន់តែដុនដាប ដេកស្លុកស្លឹងលែងដឹងខ្លួនប្រាណទៅហើយ ។

ស៊ីណាត ជាមនុស្សអសប្បុរស កាលបើឮពាក្យឪពុកម្ដាយនិយាយប្រាប់ដូច្នោះ ក្នុងចិត្តគ្មាននឹកតក់ស្លុត ឬអាណិតអាសូរអ្វីឡើយ ដោយគំនិតកំពុងតែខ្ពើមស្អប់នាងស្រាប់ផង ទើបនិយាយតបឪពុកម្ដាយវិញថា បើជម្ងឺនេះធ្ងន់ខ្លាំងមើលទៅអស់ផ្លូវលែងសង្ឃឹមហើយសូមឪពុកយកនាងទៅដាក់ឱ្យឆ្ងាយពីផ្ទះយើងចេញ ព្រោះជាជម្ងឺឆ្លងបើទុកឱ្យនៅលើផ្ទះនឹងបណ្ដាលនាំឱ្យអន្តរាយដល់ជីវិតអ្នកណាទៀតមិនខាន ។

តាប៉េង យាយស៊ឹម លុះឮសំដីកូនគួរសមឡើមដូច្នេះហាក់ដូចជាដាស់សតិគាត់ឱ្យនឹកភ័យ ទើបម្ដីម្ដាស្រែកហៅឈ្នួលប្រុសម្នាក់ឱ្យមក

ហើយប្រាប់ថា : " អាម៉ៅចូលឯងយកនាងណាត្រីទៅដាក់ឱ្យដេក លើរានមួយដែលនៅក្នុងក្រោលគោ ។ ជើងឈ្នួលក៏ទទួលតាម បង្គាប់ភ្លាម ក្រសោបលើកយកនារីចេញពីផ្ទះទៅ គាត់ក៏បបួលកូន យកកំបោរសមកបាចសាច ពាសពេញក្នុងបន្ទប់ដែលនាងដេក"។

ឱ ! គួរអាសូរ

ណាត្រី នាងត្រូវគេយកទៅបោះបង់ចោលលើរានឫស្សីចាស់ មួយដែលនៅក្នុងក្រោលគោខាងលិចផ្ទះនោះ សេចក្ដីវេទនាកើត មានទ្វេរឡើង នាងដេកលើរានស្ដឹងស្ដូកបាត់សូន្យវិញ្ញាណស្មារតី ពីក្នុងប្រាណ . . . . . . . . . . . . . . . . . . . . . . . . . .

ចំណែកមនុស្សទាំងឡាយ គ្មានអ្នកណាមួយហ៊ានដើរទៅជិត ទីដំណេកថ្មីរបស់នាងសោះឡើយ សូម្បីតែសត្វគោដែលគេធ្លាប់តែ យកទៅបញ្ចូលតាមធម្មតា គេក៏លែងហ៊ានយកទៅទុកដែរ មានតែ ផេងវិនជាក្ដួយរបស់នាងម្នាក់ទេ វារត់តាមទៅអង្គុយយំរងំនៅចុង ជើងនាង ។

# ជំពូកទី ១០
## ទេវ៉ាត្រឡប់ពីកែប ជួយណារីឱ្យរស់ឡើងវិញ

ចំណែកទេវ៉ា ចាប់តាំងពីថ្ងៃដែលបែកឃ្លាតឃ្លាចេញពីនារីទៅ អ្នកមានសេចក្ដីទុក្ខព្រួយ តប់ប្រមល់ អន្ទះអន្ទែងក្នុងប្រាណ ទើបនឹកទៅបងជីដូនមួយប្រុសម្នាក់ ដែលធ្វើការនៅក្រសួងប្រៃសណីយ៍ នៅឯកែប ។

កាលបើនឹកដូច្នោះហើយ ដើម្បីបន្ធូរទុក្ខអកុសល អ្នកក៏សូមបងស្រីធ្វើដំណើរទៅនៅឯកែប ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ថ្ងៃមួយនៅទីកែប ពេលព្រះអាទិត្យជិតផុតវេលាសន្សឹមបន្ទិចដួងទៅជើងមេឃ ដែលជាប់នឹងផ្ទៃសាគរឯណោះ ហើយចោលពន្លឺរស្មីដ៏ក្រហមឆ្អិនឆ្អៅ ច្រាលរន្ទាលឡើងអស់មួយចំហៀងនភាល័យ ឯជលធារានៃមហាសាគរ កំពុងតែរត់បណ្ដេញគ្នាលេងនៅកណ្ដាលវាលធំធេងឮសូរគគ្រាំៗ ខ្វះធំៗ ក៏បែកផ្កាត្រែង រួចស្ទុះ

ប្រមៀលប៉ះទៅច្រាំង ស្រាប់តែរលាយខ្សុលចូលគ្នាបាត់ រួចមានថ្មីប្រដេញគ្នាត១ មកទៀតបីដូចជាគ្មានចេះនឿយហត់សោះឡើយ ។ ឯគីរីដ៏ធំ១ វែងខ្ពស់ត្រដែតខំគាំទ្រវុក្ខានានា មានពណ៌បៃតងស្រស់បំព្រងហាក់ដូចជារុំសំពត់ពណ៌យ៉ាងឆើតឆាយនេះពាសពេញខ្លួន ។

វ៉ា អង្គុយនៅក្រោមដើមដូងមួយដើម ដុះក្បែរមាត់សមុទ្រនេះ វាយោគ័បក់រំភើយ១ មកគួរជាទីក្សាន្តភិរម្យត្រជាក់ដល់ដួងចិត្ត . . . . . . . . . . . . . . . . . ស្រាប់តែមេឃស្រទំជាទីរីករាយនោះក៏ក្លាយសភាពជាងងឹតអ័ព្ទស្លុបស្លុងមកភ្លាម ផ្គរក៏លាន់គ្រហឹមគគ្រុម ១ ព្រះពាយក៏បោកបក់មកដល់ បណ្តាលដើមឈើនានារំជួយរណ្តំសន្ធឹកគ្នាឮស្នូរប្រាវ១ ខ្ទះរោយរាយរសាត់ជ្រុះដល់ដី ។

ព្រះភិរុណក៏បង្អុរមកដល់ភ្លាម ហាក់បីដូចជាជួយសោកសង្រេងអាណិតដល់ណាត្រី និងវ៉ា ដែលមានសេចក្តីស្នេហាគ្នាដោយនូវវេទនាយ៉ាងដូច្នេះ . . . . . . . . . . . . . . . . . . .

បុរសកំសត់អង្គុយក្រោមដើមដូងនោះ លុះត្រឡេកឃើញមេឃងងឹតមកដល់កាលណា អ្នកក៏ខំស្ទុះម្នីម្នារត់សំដៅទីលំនៅវិញ តែឥតប្រយោជន៍ទេ សំលៀកបំពាក់អ្នកត្រូវទឹកជោកអស់ ។

លុះភ្លៀងរាំងហើយ ខ្យល់ក៏ស្ងប់ មិនយូរប៉ុន្មាននិសាករះឡើងធ្លោខាងបូព៌ាទិស ត្រេចចរក្នុងយប់ ១៤កើត បណ្តែតប្រាណ

លើនភមណ្ឌល បញ្ចាំងពន្លឺរស្មីដើម្បីបណ្ដេញស្រមោលងងឹតឱ្យថយចេញ តែមានពពករសាត់មកអន្ទាយៗ គ្របបិទបើកវង់ព្រះចន្ទឱ្យម្ដងបាត់ ម្ដងឃើញជាញយៗ ។

នៅសន្ធិយានេះហើយ ដែលវ៉ាកំពុងទម្លឹះគិតសញ្ជប់សញ្ជឹងនឹកថា :

" ឱ ! ផ្ការអើយ ! អ្នកខំបន្ទឺត្ដូញច្រូវគគ្រឹមគគ្រុមមកដាស់សតិគំនិតនៃខ្ញុំឱ្យរឭកទៅស្រុកអីម៉្លេះទេ !

ខ្លួនខ្ញុំរឹងរិតតែក្ដុកក្ដួល នឹកដល់ណាត្រីនារីរត្នពន្ធកចិត្តទ្វេរឡើងណាស់ទៅទៀត ឱ ! ណាត្រី អូន ! នាងស្មានថាបងស្ថិតនៅនាស្រុកជិតស្រើងណោះឬ ?

ឬក៏អូនដឹងថា បងបានចាកចេញឆ្ងាយមកនៅទីនេះដែរ ?

ឱ ! អូន ! ពិតមែនតែខ្លួនបងមកនៅទីឆ្ងាយអំពីថ្ងៃ គង់តែចិត្តនឹងជីវិតរបស់បងចងជាប់មកនាងគ្មានភ្លេចមួយនាទីណាសោះទេ . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

បើសិនណាជាខ្លួនបង ស៊ូទ្រាំនៅក្នុងស្រុកឯណោះសមជាបែកទ្រូងស្លាប់ពុំខាន ដោយសារយើងពុំបានជួបឃើញមុខគ្នាសោះ ។

ថ្វីបើបងបានមកនៅទីដ៏សុខសម្រាន្ត គាប់ចិត្តឯណោះដូច្នេះគង់តែបងមិនអាចបន្ទប់សេចក្ដីទុក្ខជាទម្ងន់នេះឱ្យបាត់ឡើយ ។"

យុវជននេះ អើតមើលទៅតាមបង្អួចនៅក្នុងបន្ទប់ចង្អៀតរបស់ខ្លួនសម្លឹងទៅព្រះចន្ទ ដែលកំពុងចរត្រេចក្នុងមណ្ឌលពពក ស្រាប់តែលង់ខ្លួនកប់បាត់ទៅម្តងៗ "ឱ ! ព្រះចន្ទទោះបីពពក មកពុះពាគ្របបិទអ្នកយ៉ាងនេះ សេចក្តីអត់ធន់នៅស្មៀមរបស់អ្នក អាចឱ្យពពកខ្លាចរសាត់រត់ថយទៅឯងៗ ។

ចំណែកខ្លួនខ្ញុំក៏ដូចអ្នក គឺមានគេផ្ចាញ់ផ្ចាល់ឱ្យខ្ញុំបានសេចក្តីសង្រេងសង្រៃរាល់ពេលវេលាពុំដែលដាច់ តែកាលបើខ្ញុំបានមកគយគន់ឃើញអ្នក នាំឱ្យខ្ញុំមានសេចក្តីសង្ឃឹមមាំនៅក្នុងចិត្តថា ធម្មតាមនុស្សមានធម៌ខន្តីសប្បុរស មិនដែលចាញ់កលមនុស្សពាលទ្រើសឃ្នងឡើយ ..........................

ឱ ! ជុំវិញកិសត់ខ្ញុំអើយ ! ខ្ញុំបានមកស្នាក់នៅៗ ទីនេះអស់រយៈ៣ខែហើយ ឥឡូវនេះខ្ញុំជ្រកនៅតែ ១រាត្រីនេះទៀតទេ ព្រោះសេចក្តីតប់ប្រមល់ក្នុងនិរ៉ាខ្ញុំ ស្ទុះមកខ្លាំងណាស់ហើយ ព្រឹកស្អែកនេះខ្ញុំនឹងលាចាកត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំវិញហើយ ........."

លុះព្រលឹមឡើង អ្នកក៏លាបងប្រុសចេញដំណើរវិលមកភ្នំពេញរួចបន្តទៅស្រុកគៀនស្វាយ ។

កាលបានមកនៅផ្ទះតែ ១ថ្ងៃ នៅថ្ងៃបន្ទាប់មក ពេលដែលព្រះសូរិយារលត់រស្មី វ៉ាអ្នកក៏ចេញដើរទៅកំពង់ទឹក ស្រាប់តែបាន

ប្រទះឃើញពួកស្រីដែលមានចំណាស់ៗ ឈរប្រជុំគ្នាចំនួន៤-៥ នាក់ កំពុងតែនិយាយខ្សឹបខ្សៀវគ្នាធ្វើមុខស្មើតស្លក់ ហាក់ដូចជាមានការ អ្វីមួយគួរឱ្យភិតភ័យ ។ វ៉ាក់ដើរសសៀរទៅឈរជិតជ្រៀងត្រចៀក ចាំស្តាប់ បានឮគេនិយាយប្រាប់គ្នាថា ណាត្រីមានកើតជម្ងឺ ឥឡូវនេះ គេយកទៅដាក់ចោលក្នុងក្រោលគោ ដោយខ្លាចរោគនេះឆ្លងដល់ គេ ។ វ៉ាកាលបើបានឮដូច្នោះហើយ នឹកអាសូរខ្លោចចិត្តអាណិត ដល់គួរកំសត់ណាស់ នឹកអំពីកាលនាងបានប្តូរជីវិតទៅជួយយកអាសា អ្នកឱ្យរួចពីកណ្តាប់ដៃស៊ីណាតក្នុងពេលរាត្រីមួយនោះ រួចនឹកដល់ ពាក្យដែលនាងបានសច្ចាចំពោះខ្លួន នៅក្រោមដើមស្វាយមាន ព្រះចន្ទ បញ្ចាំងរស្មីជួយធ្វើជាសាក្សីក្នុងសន្និយានោះដែរ អ្នកនឹក សព្វគ្រប់ដូច្នោះហើយ មិនអាចទប់ទឹកភ្នែកបានឡើយ ទើបទាញ ក្រម៉ាដែលបង់នៅកមកជូតទឹកភ្នែក ហើយរត់សំដៅក្រោលគោរក មើលនាង មិនយូប៉ុន្មានអ្នកក៏បានទៅដល់ ក្រឡេកមើលទៅឃើញ រូបកាយនាងប្លែកអស្ចារ្យ ស្គមនៅតែស្បែក នឹងឆ្អឹង ភ្នែករូងខូងមើល ស្ទើរមិនស្គាល់ ក្នុងចិត្តនឹកក្តុកឡើងថា ឱប្រហែលជានាងក្សិណក្ស័យ ជន្មាហើយទេដឹង ទើបអ្នកដើរចូលទៅជិតយកដៃទៅលូកស្ទាប ដង្ហើមមើលដឹងថា : នៅមានខ្យល់ដើរនៅឡើយហើយអ្នកគិតថា " គួរតែអញប្រថុយនាំយកទៅមន្ទីរពេទ្យ " ។

ចំណែកផេងរិន កាលបើឃើញបុរសនេះមកដល់ភ្លាម នាងមានសេចក្ដីត្រេកអរពន់ពេក ហើយស្ទុះទៅចាប់ដៃនិយាយអង្វរករទាំងទឹកភ្នែកថា : "ពូអើយកុំអញ្ជើញទៅណា ពូណា" អាណិតមេត្តានៅជួយមើលម៉ាក់មីងខ្ញុំផង ខ្ញុំភ័យណាស់ ដោយខ្ញុំបានឮគេថាគាត់ជិតស្លាប់"។

វ៉ា កាលបើបានឮសំដីផេងរិននិយាយដូច្នោះថែមទៀត ក្នុងទ្រូងអ្នកវីងរិតតែខ្លោចផ្សា នឹកអាសូរពាក្យក្មេងនេះជាខ្លាំង ទើបនិយាយតបទៅវិញថា" មិនអីទេក្មួយ ចាំពូជួយយកមីងនាងទៅមើលឯមន្ទីរពេទ្យនៅភ្នំពេញ ថាហើយអ្នកក៏លូកដៃទៅត្រកងបីថ្នមនារីយ៉ាងស្រួល ហើយហៅផេងរិនដើរមកតាមក្រោយសំដៅយ៉ាងលឿនតម្រង់ទៅថ្នល់ ដើម្បីហៅត្រីចក្រយានជិះ ។

ពួកអ្នកត្រីចក្រយាន កាលបើវាបានឃើញមនុស្សឈឺធ្ងន់ដូច្នោះ វាប្រកែកមិនព្រមដាក់ឡើយ ទុកតែអ្នកអង្វរករគេយ៉ាងណាក៏ដោយ វាប្រកែកធ្វើព្រងើយធាក់ហួសទៅ ។ ពេលនោះល្ងាចណាស់ទៅហើយ ត្រីចក្រយានកាន់តែតិច វ៉ាអ្នកវីងរិតតែកន្ទះរាចិត្តមិនដឹងជាគិតគ្នេរគ្នាន់ ទៅយ៉ាងណា . . . . . . . . . . . . . . . . . . . . .
. . . . . . . . . . . . . . . . . . . . . . . . . . . . . . .

* * *

"លោកអ្នកអើយ ! ក្នុងជំនាន់ហ្នឹង ប្រើគេចង់ធ្វើដំណើរទៅកាន់ទីតំបន់ណា មានតែទោចក្រយាន ត្រីចក្រយាននេះហើយ ដែលបណ្ដាជនរាប់ថាជាជំនិះដ៏គាប់ចិត្តបំផុត ក្រៅពីនេះមានតែរទេះគោរទេះសេះ ដោយហោចណាស់ទៅទៀត គឺថ្មើរជើង ពីព្រោះសម្ភារៈសំរាប់រថយន្ត ដូចយ៉ាងប្រេងសាំងជាដើមនេះគ្មានសោះ សូម្បីតែកៅស៊ូសំរាប់ទោចក្រយាន ក៏គេរកបានដោយកម្រណាស់ផង" . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

វ៉ា កំពុងតែព្រួយចិត្ត ស្រាប់តែលេចឃើញ ស៊ីណាតដើរមកដល់យុវជននេះសម្ងឹងទៅ វ៉ាដែលកំពុងត្រកងបីនារី សេចក្ដីខឹងក្ដៅក៏កើតឡើងមួយរំពេចទើបដើរទៅជិតសួរដោយពាក្យ ស្លុកសៀតថា:

ស៊ីណាត - អាវ៉ា មនុស្សល្មមតែគេមើលអស់ផ្លូវហើយ ទើបអាធ្វើបួកពួកែមកយកទៅណាហ្នឹង ?

វ៉ា - ស៊ីណាត មនុស្សមិនទាន់រលត់ជីវិត ត្រូវតែអ្នកមានចិត្តធម៌សប្បុរសរើសយកទៅមើល ។

ស៊ីណាត- អាមនុស្សអ្នកក្រអាឯង បានប្រាក់កាសមកពីណាទើបហ៊ានយកនារីនេះទៅមើល ?

វ៉ា - មនុស្សណាមានប្រាជ្ញាគេមិនបាច់អាងប្រាក់កាសទេ ។

ស៊ីណាត - អាតម្រក់ អាធ្វើខ្លួនឯងអង់អាចអ្វី បើអាទៅមេត្រី

នឹងស្រីជំរើសពីគេ ?

រ៉ា . ធម្មតាបុរសឆ្លាត គេមិនអាចបោះបង់ចោលស្រីដែលមានចិត្តស្មោះត្រង់ស៊ូប្តូរផ្តាច់ជីវិតមកលើទេ... ។

រ៉ាកុំពុងឆ្លើយតទៅស៊ីណាត ស្រាប់តែឃើញត្រីចក្រយានមួយធាក់មកដល់ជិតអ្នក ឯអ្នកត្រីចក្រយាននោះ ធ្លាប់រាប់អានរ៉ាណាស់កាលបើក្រឡេកមើលទៅឃើញដូច្នោះ វាក៏ធាក់តម្រង់មកជិតឱ្យអ្នកជិះ រ៉ា នឹកអរព្រួច ធ្វើមុខញញឹមយ៉ាងស្ងួតទៅរកអ្នកត្រីចក្រយាននោះ ។ ទើបឈានជើងឡើងទៅលើត្រីចក្រយានភ្លាម ឯដៃឱបនារីជាប់ ហើយអង្គុយបង្វែរស្រីដាក់ឱ្យដេកលើភ្លៅ ថ្នាក់ថ្នមមិនឱ្យមានឆ្គង ប្រៀបដូចជាបិតាមាតាថ្នមបុត្រ រួចហៅផេងរិនឱ្យឡើងមកជិះជាមួយ..............................

ចំណែកស៊ីណាត មានទឹកមុខស្រពោនក្រៀមក្រំថយខ្លួនដើរចេញទៅ ។

ឯត្រីចក្រយាន ក៏ចេញដំណើរទៅទាំងរាត្រីងងឹតស្ងួនស្ងាត់ហេតុតែអាយុសង្ខារនាងមិនទាន់អស់ លុះអ្នកត្រីចក្រយានធាក់បានមកដល់ជិតព្រែកឯង នាងក៏បានភ្ញាក់ស្មារតីដឹងខ្លួន ហើយបើកភ្នែកឡើង ។

រ៉ា ឃើញគូសង្សារអ្នក មានស្មារតីបើកភ្នែកឡើងដូច្នោះ

អ្នកមានសេចក្ដីត្រេកអរក្នុងចិត្តឥតឧបមា ដោយនឹកថាគូសង្សាររបស់អ្នកមុខតែរស់រានមានជីវិតពិតប្រាកដ ទើបឈ្ងោកសួរទៅនាងថា : អូនៗ នាងស្គាល់បងឬទេ ?

នារីស្រវាំងភ្នែកមើលទៅឃើញព្រិលៗ មិនស្គាល់ច្បាស់ជាអ្នកណា គ្រាន់តែនិយាយរួចខ្សាវៗ"សុំទឹកផឹក" វ៉ាក៏អង្វរអ្នកត្រីចក្រយានឱ្យឈប់ ហើយចូលទៅសុំទឹកផ្ទះគេដែលនៅតាមចិញ្ចើមថ្នល់យកមកឱ្យនាងផឹក នារីនាងបានទឹកផឹកឆ្អែតហើយ មួយសន្ទុះមកដូចជាមានកំលាំងកំហែងឡើង មើលស្គាល់ច្បាស់ជាវ៉ា ទើបសួរទៅទាំងរអាក់រអួលថា : បងម្ដេចក៏បងទៅយកខ្ញុំបានមក ? ហើយឥឡូវនេះគិតនាំខ្ញុំទៅណា ?

វ៉ា _ អូននាងឈឺជាទម្ងន់ គេយកទៅចោលក្នុងក្រោលគោបានជាបងស៊ីឈ្នួលទៅយកមក ឥឡូវនេះបងនាំនាងយកទៅមើលឯមន្ទីរពេទ្យនៅភ្នំពេញ ។

ណាត្រី _ បងបើកាលណានាំខ្ញុំយកទៅដល់មន្ទីរពេទ្យហើយសូមបងអាណិតទៅរកអញ្ជើញលោកតាមកឱ្យខ្ញុំផងណា ។ មិនយូរប៉ុន្មានត្រីចក្រយានក៏បានទៅដល់មន្ទីរពេទ្យ វ៉ានាំនាងចូលទៅផ្ដុកផ្ដាក់ស្រួលបួលហើយ ចាំឱ្យគ្រូពេទ្យចាក់ថ្នាំរួច ទើបអ្នកហ៊ានដើរចេញទៅរកបិតានាង មួយសន្ទុះក្រោយមកតាតឹមឡេងបានមកជួប

ជុំនឹងកូន.ចៅ ។

ណាត្រី កាលបើបានកំលាំងថ្នាំជួយអបស្ថម្ភ ព្រមទាំងបានជួប នឹងបិតាផង នាងក៏ហាក់ដូចជាមានកំលាំងកំហែង ទើបនិយាយ សារស័ព្ទរឿងរ៉ាវទាំងសម្លេងស្អក១ ទឹកភ្នែកហូរច្រោក១ ជំរាបទៅ ឪពុកសព្វគ្រប់ ។

តាគីមឡេង លុះបានស្តាប់កូននិយាយសារស័ព្ទរឿងសុខទុក្ខ ប្រាប់មក គាត់ក៏នឹកតូចចិត្តដល់ទៅមិត្តជាយ៉ាងក្រៃលែង ទើបមាន វាចាថា : ឯងនឹកសង្ឃឹមពឹងផ្អែកទៅលើមិត្ត ទុកចិត្តដូចជាពឹងផ្អែក ទៅលើភ្នំ មិនដឹងជាវាមានចិត្តទ្រឹស្តស្មូរជូជាតិដល់ម្ល៉េះឡើយ ។

ថាដូច្នេះហើយ គាត់បែរមើលទៅមុខវ៉ាំនិយាយថា វ៉ាំអ្នក ឯងជាក្មេងមួយមានធម៌សប្បុរស គួរឱ្យអ៊ុំសង្ឃឹមទុកចិត្តលើរូបអ្នក បាន អម្បាលកូនស្រីអ៊ុំដែលមិនជាប់ជាសាច់ញាតិ ឬជាភរិយារបស់ អ្នកក៏ទេដែរ អ្នកហ៊ានស៊ូប្តូរស្លាប់រស់យ៉ាងនេះ ឃើញថាអ្នកជា មនុស្សត្រង់ពិតប្រាកដ គួរឱ្យអ៊ុំជឿចិត្តបាន កាលណានាងបានជា សះស្បើយរោគនេះ អ៊ុំនឹងរៀបចំផ្សំផ្គុំឱ្យអ្នក ។

ពីរថ្ងៃក្រោយមក នារីកាន់តែមានកំលាំងកំហែងគ្រាន់បើ ឡើង១ នាំឱ្យនាងទុកចិត្តថា រោគនេះមុខជាបានជាសះស្បើយមិន ខាន ទើបនាងហៅវ៉ាំមកជិតហើយនិយាយថា : បងសូមទៅរក

ជួលផ្ទះឯណា ដែលមានថ្លៃឈ្នួលថោកគួរសម ហើយមើលឱ្យល្មមនឹងយើងធ្វើជំនួញបានផង រួចបងយកចិញ្ចៀនពេជ្ររបស់ខ្ញុំនេះទៅលក់ឱ្យខ្ញុំផង ដើម្បីយើងយកប្រាក់មកធ្វើដើមទុនរកស៊ី ។

វ៉ា ‑ ប្អូន បងមានសល់មាសពីរដម្លឹង ដែលជាកេរ្តិ៍របស់ឪពុកម្តាយបងចែកទុកឱ្យមក ចាំបងទៅយកមកឱ្យនាងលក់បានប្រាក់ទុកផ្សំគ្នាចុះ ប៉ុន្តែចំណែកចិត្តបងៗ ចង់ទៅសុំការរាជការធ្វើ ព្រោះបងបានប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់ដែរ . . . . . . . . . . . . . . .

ណាត្រី ‑ យីបង ! កុំប្រាថ្នាទៅធ្វើការរាជការ ព្រោះក្នុងប្រទេសយើងមិនសូវមានជាតិខ្មែរធ្វើជំនួញប៉ុន្មានទេ មានតែជាតិគេដទៃៗ សឹងតែគ្រប់ទីដំបន់ ចូរបងសម្លឹងមើល ដូច្នេះបងកុំរេរាចិត្តត្រូវតែយើងខិតខំខាងជំនួញទៅវិញទៅ បើយើងមានតម្រេះវិជ្ជាដូច្នេះផងរឹងរិតតែគាប់ប្រសើរណាស់ទៅទៀត យើងនឹងមានសង្ឃឹមថាផ្លូវជំនួញរបស់យើង មុខតែរីកទូលាយថែមឡើងជាលំដាប់មិនខាន ។

* * *

ណាត្រី_បងវ៉ា គូសង្សារ អស់សង្ស័យ
ចូរអ្នកថ្លៃ មាសថ្លើមប្អូន យកចិញ្ចៀន
ទៅលៃលក បញ្ចាំលក់ កុំអៀនប្រៀន
ដើមទុនរៀន រិះរកទ្រព្យ តាមបំនា ។
ប្អូនស្រណោះ បងវ៉ា ម្ញប់រំជួល
ចិត្តក្តុកក្តួល ប្អូនភក្តី ជួបភ័ក្ត្រា
នៅទីវាល ចិត្តវិលវល់ ព្រឹកាយា
យើងចរចា អាទិត្យចាំង នៅចុងឈើ ។
ស្រណោះស្រី ចិត្តស្រើបស្រួល មិនយល់កល្ប
ចិត្តក្នុងឆ្ងល់ មុខជ្រប់អៀន ភ័យចិត្តរើ
ក្នុងរាវែក ខ្លួនរិះរក កិច្ចកល្បប្រើ
ព្យាយាមធ្វើ បូកមិនធ្វេស ឱ្យបង់កេរ្តិ៍ ។
វ៉ា_ប្អូនណាត្រី ដូចវារី ថ្លាត្រជាក់
ចងចិត្តស្ម័គ្រ គ្មានគិតស្មាន ស្មោះរិះរេ
ថាជួបប្អូន ក្នុងពេលនេះ ចិត្តគ្មាន់គ្នេ
ជោគវៀចវេ វាសនាវិល វាត់មកជិត ។
បងមិនភ្លេច គុណប្អូនគន់ កាលស៊ីណាត
ចង់សម្លាប់ បងរាត្រី យប់ងងឹត

សាមីទាន បងគោរព បូជាពិត
កុំវរមិត្ត នាងជួយបង ក្ស័យជន្មា ។
បងមិនទាន់........................ ........
ណាត្រី ...... កុំបងថា នាងមិនគិត
វ៉ានិក កាលប្អូនឈឺ ជួយបានជា
គួរពឹងបាន ប្រុសប្ដូរប្រាណ មិនរួញរា
កែវពុំងា ចិត្តមិនងាក ពីប្រុសឆ្មើម ។
ប្អូនបំណង ចិត្តចងជាប់ ..............
វ៉ា .................... តែខាងបង
មានបំណង ចង់ធ្វើការ ណាមាសថ្លើម
ណាត្រី ...... ធ្វើពាណិជ្ជណាអ្នកបង តាមគង់ដើម
ដើមទុនផ្ដើម យើងផ្លាស់ប្ដូរ ប្រមូលទ្រព្យ ។
ខ្មែរឥឡូវ ធ្វើជំនួញ កិចណាស់បង
គួរចាំបង ចិត្តបំណង ជួញមានភ័ព្វ
កើតសេដ្ឋី បានសួស្ដី កបក្ដីគាប់
តាមទម្លាប់ ម៉ែឪយើង ពីបូរាណ ។

* * *

លុះកន្លងកន្លះខែក្រោយមក តាគឹមឡេងគាត់ជ្រើសរើសបាន ថ្ងៃខែល្អក៏រៀបចំអាពាហ៍ពិពាហ៍ កូនស្រីគាត់ឱ្យធ្វើជាភរិយាវ៉ា ។

អ្នកទាំងពីរនាក់នេះ នៅរួមសុខទុក្ខជាមួយគ្នាឥតមានមោះ ហ្មងអ្វីឡើយ ។ ណាត្រីពិតមែនតែនាងជាស្រី ប៉ុន្តែនាងមានចិត្ត ក្លាហានអាចដឹកនាំបបួលស្វាមីឱ្យធ្វើជំនួញបាន ហើយនាងយកឪពុក នឹងក្មួយមកនៅជាមួយខំបីបាច់ថែរក្សា មិនយូរប៉ុន្មានសង្គ្រាមក៏ឈប់ ច្បាំង ។

គ្រួសារនេះធ្វើរបរក៏កាន់តែកើនចំរើនឡើង ហើយនៅសុខ សប្បាយជាមួយគ្នាដរាបតរៀងទៅឥតរលកដង្គំគ្នាឡើយ ។

= ចប់ =

បោះពុម្ពចប់ក្នុងឆមាសទី១ ព.ស. ២៥៤៣ គ.ស. ១៩៩៩
Imprimé au Cambodge : *Printed in Cambodia*
par **AIK** ( Atelier d'Impression Khmère du Cedoreck )
*by **AIK** ( Cedoreck's Khmer Printing house )*
Dépôt légal : 1er trimestre 1999
*Registration of copyright : beginning of 1999*
**ISBN 2-86731-040-7**

## គតិអ្នកនិពន្ធ :

មានភោគទ្រព្យខ្ញុំ ចិត្តអាក្រក់ មិនសោភ័ណ
ក្រធន់គ្រាន់ មនោល្អ ស្វាមីភក្តិ
ពូជសេដ្ឋី ចិត្តប្រិមប្រិយ ក្រស្មោះស្ម័គ្រ
ក្រមាសប្រាក់ ចិត្តអបល័ក្ខណ៍ កុំឱ្យយល់ ។
វ៉ា ប្រុស ក្រទ្រព្យប្រាក់ ចិត្តសប្បុរស
គួរពឹងស្មោះ រំពឹងចិត្ត ល្អសពល
ទ្រព្យភោគកល មាសប្រាក់កែវ កើតខាងក្រោយ ។

មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ

**CEDORECK**

**CENTRE DE DOCUMENTATION**
**ET DE RECHERCHE SUR LA CIVILISATION KHMÈRE**
***RESOURCE AND RESEARCH CENTRE ON KHMER CIVILAZATION***

លេខ ២០១ ផ្លូវ ៦៣ ភ្នំពេញ N° 201 rue 63, Phnom Penh

B.P. 419 - Phnom Penh
E-mail : CEDORECK @ worldmail.com.kh

រោងពុម្ពខ្មែរ A.I.K.

ISBN 2-86731-040-7